**និទានកថា**
**EDITORIAL**

# តួនាទីដ៏ធំធេងរបស់គណបក្សប្រជាជនកម្ពុជាក្នុងការស្វែងរកដំណោះស្រាយនយោបាយជូនជាតិ

# CPP's Key Role in Search of National Political Settlement

បញ្ហាតានតឹងខាងនយោបាយដែលបានកើតឡើងក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៥ ត្រូវបានដោះស្រាយហើយ នៅក្នុងជំនួបកំពូលរវាងថ្នាក់ដឹកនាំនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ នៅវិមានព្រឹទ្ធសភា ។ គណបក្សទាំងពីរបានឯកភាពគ្នាលើដំណោះស្រាយនយោបាយដោយចូលរួមធ្វើការជាមួយគ្នានៅក្នុងស្ថាប័នរដ្ឋសភាឯកភាពគ្នាដើម្បីកែទម្រង់ការបោះឆ្នោត ជាពិសេសការរៀបចំស្ថាប័នបោះឆ្នោតដោយមានចែងក្នុងជំពូកមួយនៃរដ្ឋធម្មនុញ្ញ ឯកភាពគ្នាកំណត់ឡើងវិញនូវកាលបរិច្ឆេទសម្រាប់ការបោះឆ្នោតនាពេលខាងមុខ និងឯកភាពគ្នាក្នុងការរៀបចំក្បាលម៉ាស៊ីនរដ្ឋសភា ។ គណបក្សទាំងពីរក៏បានឯកភាពគ្នាក្នុងការពិនិត្យរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនព្រឹទ្ធសភា ព្រមទាំងឯកភាពគ្នាធ្វើការកែទម្រង់ស្ថាប័នជាតិសំខាន់ៗដើម្បីធានាប្រសិទ្ធភាពក្នុងការបំពេញការងារបម្រើជាតិ និងប្រជាជនស្របតាមគោលការណ៍ប្រជាធិបតេយ្យ និងនីតិរដ្ឋ ។ ឆ្លងតាមជោគជ័យនេះបានបង្ហាញឱ្យឃើញច្បាស់ថា មានតែការចរចាគ្នាដោយសន្តិវិធីរវាងខ្មែរនិងខ្មែរទេទើបអាចដោះស្រាយបញ្ហាជាតិបាន ដែលស្របទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ។ ការធ្វើបាតុកម្មបង្កចលាចលក្នុងសង្គមមិនមែនជាដំណោះស្រាយទេ ប៉ុន្តែវាគ្រាន់តែជំរុញឱ្យសង្គមជាតិទទួលរងការខាតបង់ និងអស្ថិរភាពប៉ុណ្ណោះ ។

គួររំឭកថា អស់រយៈពេលជិតមួយឆ្នាំកន្លងទៅនេះ គណបក្សប្រឆាំងបានបង្កើតឱ្យមានសភាពការណ៍ ដ៏តានតឹងស្មុគស្មាញជាប្រចាំតាមរយៈសកម្មភាពប្រឆាំងជាច្រើនរូបភាព ជាពិសេសការធ្វើបាតុកម្មតាមដងផ្លូវ និងទីសាធារណៈយ៉ាងអនាធិបតេយ្យរហូតក្លាយជាកុប្បកម្មដ៏ហិង្សា ។ ក្នុងបរិការណ៍នេះគណបក្សប្រជាជនកម្ពុជា ដែលជាគណបក្សឈ្នះឆ្នោត បានប្រកាន់គោលជំហរនយោបាយប្រកបដោយការទទួលខុសត្រូវដើម្បីការពារស្ថិរភាពនយោបាយនិរន្តរភាពរបស់រដ្ឋនិងប្រក្រតីភាពនៃជីវភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាជន ។ ទន្ទឹមនេះគណបក្សប្រជាជនកម្ពុជាបានខិតខំស្វែងរកដំណោះស្រាយនយោបាយជាមួយគណបក្សប្រឆាំងប្រកបដោយភាពស្មោះសរបំផុត ដោយបានធ្វើការសម្របសម្រួល និងសម្បទានជាបន្តបន្ទាប់នៅក្នុងការចរចាទាំងការចរចានៅកម្រិតក្រុមការងារបច្ចេកទេសជាច្រើនលើក និងការចរចាថ្នាក់កំពូល ។ ប៉ុន្តែការចរចាត្រូវអូសបន្លាយមិនទទួលបានលទ្ធផលល្អឡើយ អាស្រ័យដោយគណបក្សប្រឆាំងនៅតែទាមទារនូវលក្ខខណ្ឌនានាដែលមិនស្របតាមរដ្ឋធម្មនុញ្ញ និងស្ថានភាពពិតប្រាកដនៅកម្ពុជា ។ រហូតមកដល់ថ្ងៃទី ២២ ខែកក្កដានេះ គឺមួយអាទិត្យក្រោយព្រឹត្តិការណ៍កុប្បកម្មដ៏ហិង្សានៅក្បែរទីលានប្រជាធិបតេយ្យ( ថ្ងៃទី

On 22 July 2014, the political tension arisen from the fifth legislative term of the National Assembly's general election has been resolved in the summit of leaders of the Cambodian People's Party (CPP) and the Cambodian National Rescue Party (CNRP). The two parties have agreed on a political settlement, working together in the National Assembly, conducting electoral reform, chaptering the electoral institution in the Constitution, while setting a new date for the forthcoming elections and rearranging the National Assembly's leadership structure.

The two parties will review the leadership structure of the Senate and reform key national institutions aimed at securing effectiveness in serving our nation and people in accordance with the principle of democracy and rule of law. The scored achievement clearly shows that peaceful negotiation among Cambodians is the only way to solve the national problems to suit the people's aspiration. Turmoil inflicting demonstrations in the society was not a solution but a recipe for national loss and destabilization.

It is worth recalling that over the past nearly one year, the opposition party regularly created complicate situations through various forms, especially street protests and anarchic public demonstrations leading to violence. In that context, the elections-winning Cambodian People's Party has always adhered responsibly to political position in safeguarding political stability and ensuring state sustainability as well as people's regular socio-economic livelihood.

Simultaneously, the Cambodian People's Party faithfully sought for a political solution with the opposition party while making reconciliatory and concessional offers one after the other at the technical teams as well as in the top-level negotiations. The negotiation, however, did not come to a positive result since the opposition party demanded for conditions that were unconstitutional and unrealistic to the Cambodian situation. Until 22 July 2014, one week after the 15-July violence-led protest event at the democratic park, the two parties have reached the solution ceasing the dragging post-election tension.

The Agreement on Political Settlement between the two parties on July 22 is indeed a victory for the whole nation and hailed by international community. The agreement contains significant meanings as followed:

- The settlement entirely reflects the political position of the Cambodian People's Party to have adhered steadfastly since after the elections. Those positions are:

•Demonstration as carried out by the opposition party is not a solution. Only negotiation can solve the problem. No foreign nation can solve the issues on Cambodians' behalf.

•Settlement must base on results of the elections, in which CPP has won 68 seats and CNRP 55 seats in the National Assembly.

•Settlement must base on Constitution, existing laws and legal tools in conformity with principles of democracy and rule of law.

•Settlement must stem out from faithful national reconciliation spirit that all are working together in the supreme interest of our nation and people.

- The settlement obviously shows faithfulness, capability and responsibility of the 35 years-experienced CPP in leading the country. CPP adheres steadfastly to the policy of peace and national reconciliation, while making adjustment and concession aimed at resolving internal issues of the country.

- The settlement also sets light on the fact that the more than one-year political tension - which brought about violence one after the other, sustained damage to security and public and private property, caused injuries among people and competent authorities, while inflicting disfavor cloud in investment and business – was mistake of opposition political leaders. They must avoid creating

១៥ ខែកក្កដា ឆ្នាំ ២០១៤) ទើបគណបក្សទាំងពីរអាចសម្រេចបាននូវដំណោះស្រាយដែលបានបញ្ចប់នូវសភាពការណ៍តានតឹងតាំងពីក្រោយការបោះឆ្នោតមក ។ កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរវាងគណបក្សទាំងពីរ នាថ្ងៃទី ២២ ខែកក្កដា នេះ គឺជាជោគជ័យសម្រាប់ជាតិទាំងមូល ហើយទទួលបាននូវការសាទរពីសហគមន៍អន្តរជាតិ ។

ពិនិត្យលើខ្លឹមសារនៃដំណោះស្រាយនយោបាយនេះ យើងអាចដកចេញបាននូវអត្ថន័យសំខាន់ៗដូចខាងក្រោម :

-ដំណោះស្រាយបានឆ្លុះបញ្ចាំងទាំងស្រុងនូវគោលជំហរនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ដែលបានប្រកាន់ខ្ជាប់តាំងពីក្រោយការបោះឆ្នោតមក ។ គោលជំហរនោះគឺ :

-បាតុកម្មដែលគណបក្សប្រឆាំងបានធ្វើ មិនមែនជាដំណោះស្រាយទេ មានតែការចរចាប៉ុណ្ណោះទើបអាចដោះស្រាយបញ្ហាបាន ហើយគ្មានបរទេសណាអាចមកដោះស្រាយបញ្ហាខ្មែរជួសខ្មែរបានឡើយ ។

-ដំណោះស្រាយត្រូវផ្អែកលើមូលដ្ឋានលទ្ធផលនៃការបោះឆ្នោត គឺគណបក្សប្រជាជនកម្ពុជាឈ្នះឆ្នោតទទួលបាន៦៨អាសនៈក្នុងរដ្ឋសភា ឯគណបក្សសង្គ្រោះជាតិទទួលបាន ៥៥ អាសនៈក្នុងរដ្ឋសភា ។

-ដំណោះស្រាយត្រូវផ្អែកលើរដ្ឋធម្មនុញ្ញ ច្បាប់ និងបទដ្ឋានគតិយុត្តិជាធរមាន ហើយត្រូវស្របនឹងគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី និងនីតិរដ្ឋ ។

ដំណោះស្រាយត្រូវផ្តើមចេញពីស្មារតីបង្រួបបង្រួមជាតិផ្សះផ្សាជាតិយ៉ាងស្មោះសរ ដោយត្រូវរួមគ្នាធ្វើការក្នុងផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់ប្រទេសជាតិ និងប្រជាជន ។

-ដំណោះស្រាយបានបង្ហាញច្បាស់នូវភាពស្មោះត្រង់ សមត្ថភាព និងការទទួលខុសត្រូវរបស់គណបក្សប្រជាជនកម្ពុជា ដែលបានដឹកនាំប្រទេសជាង ៣៥ ឆ្នាំមកហើយនោះ ដោយប្រកាន់ខ្ជាប់នូវនយោបាយសន្តិភាព និងការបង្រួបបង្រួមជាតិ ខិតខំធ្វើការសម្របសម្រួល និងសម្បទាន ដើម្បីដោះស្រាយបញ្ហាផ្ទៃក្នុងរបស់ជាតិ ។

-តាមរយៈដំណោះស្រាយធ្វើឱ្យឃើញយ៉ាងច្បាស់ថាសភាពការណ៍តានតឹងខាងនយោបាយរយៈពេលជាងមួយឆ្នាំរហូតបង្កជាអំពើហិង្សា ១ លើក ជា ២ លើក ធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ទ្រព្យសម្បត្តិរដ្ឋ និងឯកជន បង្ករបួសស្នាមដល់ប្រជាជន និងកម្លាំងមានសមត្ថកិច្ច ព្រមទាំងជះឥទ្ធិពលដល់បរិយាកាសវិនិយោគ និងធុរកិច្ច គឺជាកំហុសរបស់អ្នកដឹកនាំនយោបាយប្រឆាំងដែលបានធ្វើឱ្យកើតមានឡើង ។ គេត្រូវចៀសវាងកុំបង្កើតឱ្យមានបញ្ហាបែបនេះតទៅមុខទៀត ។

-ដំណោះស្រាយបានបញ្ចប់នូវភាពតានតឹងខាងនយោបាយ ហើយនាំមកនូវក្តីសប្បាយរីករាយសម្រាប់ប្រជាជនកម្ពុជានៅទូទាំងប្រទេស និងការលើកទឹកចិត្តពីសហគមន៍អន្តរជាតិ ។ តាមរយៈដំណោះស្រាយនេះ បានរាំងស្កាត់គ្រោះថ្នាក់នៃការបែកបាក់ជាតិ ហើយនឹងបន្តពង្រឹងពង្រីកនូវបរិយាកាសស្រុះស្រួលគ្នាក្នុងសង្គមជាតិ ។ ព្រមជាមួយនេះ បានបង្កភាពអនុគ្រោះថែមទៀតដល់ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងការអភិវឌ្ឍ ។

-ដំណោះស្រាយបានបង្ហាញនូវភាពចាស់ទុំនយោបាយរបស់គណបក្សដែលមានអាសនៈក្នុងរដ្ឋសភា ក្នុងការរួមសហការគ្នាដើម្បីបម្រើប្រយោជន៍ជាតិ និងប្រជាជន ។

ប្រជាជនកម្ពុជាទូទាំងប្រទេសបានសម្តែងនូវក្តីសប្បាយរីករាយយ៉ាងខ្លាំងចំពោះដំណោះស្រាយនយោបាយនេះ ហើយសង្ឃឹមថា ចាប់ពីពេលនេះទៅនឹងលែងមានការធ្វើបាតុកម្មដ៏អនាធិបតេយ្យ ការធ្វើកុប្បកម្ម និងការបង្កចលាចលក្នុងសង្គមទៀតហើយ ។ គណបក្សទាំងពីរនឹងចូលរួមធ្វើការជាមួយគ្នាក្នុងស្ថាប័នរដ្ឋសភា ដើម្បីដោះស្រាយបញ្ហានានារបស់ប្រទេសជាតិ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ។ គណបក្សទាំងពីរនឹងត្រូវប្រឹងប្រែងដើម្បីពង្រីកប្រជាប្រិយភាពរបស់ខ្លួន តាមរយៈការបង្កើតសមិទ្ធផលពិតក្នុងការបម្រើប្រជាជន ។ ដំណោះស្រាយនេះក៏បានឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ថែមទៀតនូវតួនាទីដ៏ធំធេងរបស់គណបក្សប្រជាជនកម្ពុជា ដែលក្នុងរយៈពេលជិត៣៦ឆ្នាំកន្លងទៅនេះ បានធ្វើអ្វីៗគ្រប់យ៉ាងដើម្បីសន្តិភាពស្ថិរភាព ការបង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ និងវឌ្ឍនភាពនៃមាតុភូមិ និងប្រជាជនកម្ពុជា ។ ដោយឡែកគណបក្សសង្គ្រោះជាតិត្រូវតែបង្ហាញនូវទឹកចិត្តស្មោះសរ និងសុឆន្ទៈពិតប្រាកដក្នុងការអនុវត្តស្មារតីនៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយនេះ ។/

ទស្សនាវដ្តីប្រជាជន

this kind of problem in the future.

- The settlement, while putting an end to political tension and bringing about joy for people in the whole country, also gives encouragement to the international community. It prevents the country from national division and ensures continued strengthening and expanding national reconciliatory environment. Not least, the settlement furthers political stability, security, social order and development.

- The settlement underlines political maturity of political parties winning seats in the National Assembly to work together to serve national and people's interests.

The Cambodian people in the whole country express joys for the political settlement with a firm hope that from now on there will be no more anarchic demonstration, protest and turmoil-driven actions in our society. The two parties will be working together in the National Assembly to solve every national problem in accordance with the principle of democracy and rule of law. The two parties must make efforts to expand popularity through creation of real achievements in service to the people. The settlement further reflects the key role of the Cambodian People's Party, who, in the past 36 years, has been doing everything for peace, stability, national reconciliation, democracy and progress for the motherland and people. CNRP must therefore express its faithfulness and true will in implementing the spirit of this agreement on political settlement./.

THE PRACHEACHUN MAGAZINE

## កិច្ចព្រមព្រៀង
## ស្ដីពី
## ដំណោះស្រាយនយោបាយរវាងគណបក្សប្រជាជនកម្ពុជា និង គណបក្សសង្គ្រោះជាតិ

- ដោយយល់ឃើញថា ដំណោះស្រាយដោយសន្តិវិធីតាមរយៈការចរចា គឺជាមធ្យោបាយដ៏ល្អតែមួយគត់ក្នុងការដោះស្រាយបញ្ហានយោបាយដែលកើតមាន ក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៥ នៃរដ្ឋសភា នាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣
- ដោយគោរពតាមឆន្ទៈរបស់ប្រជាពលរដ្ឋ និងដើម្បីជាផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមនៃប្រទេសជាតិ

ថ្នាក់ដឹកនាំកំពូលនៃ **គណបក្សប្រជាជនកម្ពុជា** និង **គណបក្សសង្គ្រោះជាតិ** បានជួបប្រជុំពិភាក្សាគ្នា នាថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៤ នៅវិមានព្រឹទ្ធសភា និងបានព្រមព្រៀងគ្នាលើដំណោះស្រាយនយោបាយ ដែលមានខ្លឹមសារដូចខាងក្រោម ៖

**ប្រការ ១ .-**

គណបក្សទាំងពីរបានឯកភាពគ្នាលើដំណោះស្រាយនយោបាយ ដោយចូលរួមធ្វើការជាមួយគ្នានៅក្នុងស្ថាប័នរដ្ឋសភា ដើម្បីឈានទៅដោះស្រាយបញ្ហានានារបស់ប្រទេសជាតិ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ។

**ប្រការ ២ .-**

ផ្អែកតាមស្មារតីនៃសេចក្ដីប្រកាសរួមនៃជំនួបកំពូលរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិកាលពីថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១៣ គណបក្សទាំងពីរបានឯកភាពគ្នាដើម្បីកែទម្រង់ការបោះឆ្នោតដោយរៀបចំស្ថាប័នរៀបចំការបោះឆ្នោតជាស្ថាប័ន ដែលមានឯករាជ្យពេញលេញដោយមានចែងក្នុងជំពូកមួយដោយឡែកក្នុងរដ្ឋធម្មនុញ្ញ ហើយសមាសភាពនៃស្ថាប័ននេះ ត្រូវជ្រើសតាំងដោយរដ្ឋសភាតាមមតិភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។ សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានចំនួន ០៩ រូប ក្នុងនោះ សមាសភាព ០៤ រូប ជ្រើសរើសដោយគណបក្សដឹកនាំរាជរដ្ឋាភិបាល, សមាសភាព ០៤ រូប ជ្រើសរើសដោយគណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ហើយសមាសភាព ០១ រូបទៀត គឺត្រូវជ្រើសរើសដោយមានការព្រមព្រៀងគ្នារវាងគណបក្ស ដែលមានអាសនៈក្នុងរដ្ឋសភា ។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា ត្រូវដំណើរការរៀបចំឱ្យមានការជ្រើសរើសដោយបើកចំហ និងតម្លាភាព នូវសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដាក់ជូនរដ្ឋសភាដើម្បីបោះឆ្នោតទុកចិត្ត ។ ក្នុងករណីដែលខកខានមិនបានរៀបចំសមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សមាសភាពគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានស្រាប់ត្រូវបន្តការងាររបស់ខ្លួនបន្តទៀត និងមានសមត្ថកិច្ចដើម្បីចាត់ចែងរៀបចំការបោះឆ្នោតតាមច្បាប់ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានថវិកាស្វយ័តសម្រាប់ដំណើរការ ។

គណបក្សទាំងពីរឯកភាពគ្នាឱ្យគណៈកម្មការចម្រុះដែលមានស្រាប់ បន្តពិភាក្សាគ្នារៀបចំក្របខណ្ឌកំណែទម្រង់ការបោះឆ្នោតនាពេលខាងមុខ ស្របតាមសេចក្ដីប្រកាសរួមរវាងក្រុមការងារគណបក្សប្រជាជនកម្ពុជា និងក្រុមការងារគណបក្សសង្គ្រោះជាតិ កាលពីថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ២០១៤ ក្នុងនោះ ដោយរួមទាំងការរៀបចំបញ្ជីឈ្មោះបោះឆ្នោតជាថ្មី ។

**ប្រការ ៣ .-**

គណបក្សទាំងពីរឯកភាពគ្នាកំណត់ឡើងវិញ នូវកាលបរិច្ឆេទសម្រាប់ការបោះឆ្នោតនាពេល

ខាងមុខ ។

**ប្រការ ៤ .-**

គណបក្សទាំងពីរឯកភាពគ្នាក្នុងការរៀបចំឱ្យមានការបែងចែកអំណាចដាច់ពីគ្នា រវាងអំណាចនីតិប្បញ្ញត្តិ និងអំណាចនីតិប្រតិបត្តិ ។ គណបក្សទាំងពីរឯកភាពគ្នាធ្វើការសិក្សា ដើម្បីឈានទៅធ្វើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ដើម្បីឱ្យស្ថាប័ននេះអាចបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ និងកាន់តែមានប្រសិទ្ធភាព ក្នុងនោះ លើកកំពស់តួនាទី និងសិទ្ធិអំណាចរបស់គណបក្សមានអាសនៈក្នុងរដ្ឋសភាដែលមិនចូលរួមក្នុងរាជរដ្ឋាភិបាល ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ គណបក្សទាំងពីរឯកភាពគ្នារៀបចំក្បាលម៉ាស៊ីនរដ្ឋសភា ដោយបែងចែកតួនាទីដឹកនាំនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា តាមរូបមន្ត ៧ ទល់ ៦ ដោយត្រូវបង្កើតបន្ថែម គណៈកម្មការជំនាញថ្មីមួយទៀត ហើយដោយមានប្រធានរដ្ឋសភាមកពីគណបក្សប្រជាជនកម្ពុជា, អនុប្រធានទី ១ មកពីគណបក្សសង្គ្រោះជាតិ និងអនុប្រធានទី ២ មកពីគណបក្សប្រជាជនកម្ពុជា ។ គណៈកម្មការដែលបង្កើតថ្មីជាគណៈកម្មការទី ១០ មានឈ្មោះថា "គណៈកម្មការអង្កេត បោសសំអាត និងប្រឆាំងអំពើពុករលួយ" ដោយបំបែកចេញពីគណៈកម្មការទី ៤ ហើយដូរឈ្មោះគណៈកម្មការទី ៤ មកជា "គណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ"។ គណៈកម្មការដែលគណបក្សប្រជាជនកម្ពុជាធ្វើជាប្រធាន និងធ្វើជាលេខាធិការ រួមមាន គណៈកម្មការទី ២, គណៈកម្មការទី ៤, គណៈកម្មការទី ៥, គណៈកម្មការទី ៦ និង គណៈកម្មការទី ៩ ។ គណៈកម្មការដែលគណបក្សសង្គ្រោះជាតិធ្វើជាប្រធាន និងធ្វើជាលេខាធិការ រួមមាន គណៈកម្មការទី ១, គណៈកម្មការទី ៣, គណៈកម្មការទី ៧, គណៈកម្មការទី ៨ និង គណៈកម្មការទី ១០ ។ គណៈកម្មការនីមួយៗមាន០៩រូប ។គណៈកម្មការដែលគណបក្សណាធ្វើជាប្រធាន គណបក្សនោះមាន០៥រូប និងគណបក្សមួយទៀតមាន ០៤ រូប ។

**ប្រការ ៥ .-**

គណបក្សទាំងពីរឯកភាពគ្នាពិនិត្យរៀបចំឡើងវិញនូវក្បាលម៉ាស៊ីនដឹកនាំព្រឹទ្ធសភា ។

**ប្រការ ៦ .-**

គណបក្សទាំងពីរឯកភាពគ្នាធ្វើការកែទម្រង់ និងពង្រឹងស្ថាប័នជាតិសំខាន់ៗ ជាពិសេសស្ថាប័នឯករាជ្យនានាឱ្យអាចបំពេញការងារបម្រើជាតិ និងប្រជាពលរដ្ឋ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងនីតិរដ្ឋ ។

**ប្រការ ៧ .-**

គណបក្សទាំងពីរឯកភាពគ្នាក្នុងការសិក្សា ដើម្បីឈានទៅធ្វើវិសោធនកម្មបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីធានាការអនុវត្តកិច្ចព្រមព្រៀងនេះ ។

**តំណាងគណបក្សប្រជាជនកម្ពុជា** | **តំណាងគណបក្សសង្គ្រោះជាតិ**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** | **ឯកឧត្ដម សម រង្ស៊ី**

**ឯកឧត្ដម សាយ ឈុំ** | **ឯកឧត្ដម ស ខេង** | **ឯកឧត្ដម កឹម សុខា** | **ឯកឧត្ដម ប៉ុល ហំម**

# ជួញជិតប្រសើរជាងជួញឆ្ងាយ

ស្ទើរពេញមួយអំឡុងខែមិថុនាឆ្នាំ២០១៤ពលករចំណាកស្រុកខ្មែរត្រូវរបបយោធាថៃចាប់បញ្ជូនទាំងបង្ខំឱ្យវិលមកកម្ពុជាវិញមានចំនួនជាង ២៤ ម៉ឺននាក់ ។ ការបណ្តេញពលកររាប់សែននាក់ឱ្យចេញយ៉ាងគំហុកពីប្រទេសថៃបែបនេះ ត្រូវបានគេចាត់ទុកថាជាអំពើអសីលធម៌ គ្មានការទទួលខុសត្រូវ ព្រោះវាបានបង្កឱ្យពលករខ្មែរទទួលហានិភ័យខ្ពស់មិនមានសុវត្ថិភាព។ ម្យ៉ាងវិញទៀតរបបយោធាថៃក៏មិនបានជូនដំណឹង ឬក៏ពិភាក្សាជាមួយភាគីកម្ពុជាឡើយ ឬយ៉ាងហោចណាស់ក៏ត្រូវពិភាក្សាការងារជាមួយនឹងអាជ្ញាធរនៃបណ្តាខេត្តដែលនៅជាប់តាមបណ្តោយព្រំដែននោះផងដែរ។ បើទោះបីជាក្រោយមកមេដឹកនាំនៃរបបយោធាថៃបានសម្តែងឥរិយាបថទន់ភ្លន់ និងហាក់ដូចជាទទួលស្គាល់នូវកំហុសឆ្គងរបស់ខ្លួនក៏ដោយ ប៉ុន្តែពលករកម្ពុជាបានប្រឈមមុខនឹងការលំបាករួចទៅហើយដោយសារតែការបណ្តេញចេញនេះ ។ជាមួយនេះក៏មានកើតនូវការបាញ់ប្រហារទៅលើរថយន្តដឹកពលករពីសំណាក់ពួកទាហានថៃដែលធ្វើឱ្យរថយន្តជួបគ្រោះថ្នាក់បណ្តាលឱ្យពលករខ្មែរស្លាប់ និងរបួសជាច្រើននាក់ ដែលនេះជាទង្វើអសីលធម៌ អមនុស្សធម៌ និងព្រៃផ្សៃ មិនផ្អែកទៅលើច្បាប់ទម្លាប់ ការយោគយល់ និងសម្របសម្រួលក្នុងឋានៈជាប្រទេសជិតខាងភូមិផងរបងជាមួយ ។ ជាការពិតហើយពលករចំណាកស្រុកទាំងនោះជាពលករខុសច្បាប់ ប៉ុន្តែគេក៏មិនត្រូវប្រមាថដល់អាយុជីវិតរបស់បងប្អូនទាំងនោះទេ។ ប៉ុន្តែទោះជាយ៉ាងណាមកដល់ពេលនេះ អាស្រ័យដោយទំនាក់ទំនងរវាងមេដឹកនាំនៃរបបយោធាថៃជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកែសម្រួលធ្វើឱ្យពលករកម្ពុជាបានក្លាយទៅជាពលករស្របច្បាប់ តាមរយៈការធ្វើលិខិតស្នាមផ្សេងៗ ក៏មានពលករ កម្ពុជាមួយចំនួនបានវិលត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញក្នុងភាពជាពលករស្របច្បាប់ ។

គួររំឭកថា ការបណ្តេញពលករក្នុងទ្រង់ទ្រាយធំបែបនេះក៏បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សេដ្ឋកិច្ចរបស់ថៃផងដែរដែលក្នុងនោះប៉ះពាល់ខ្លាំងទៅលើវិស័យកសិកម្ម នេសាទ សំណង់ ទេសចរណ៍ និងបដិសណ្ឋារ-កិច្ច ។វិស័យកសិកម្ម និងសំណង់រងផលប៉ះពាល់ខ្លាំងជាងគេ ពិសេសនៅភាគខាងកើតប្រទេសថៃ ។ ការបណ្តេញយ៉ាងគំហុកនេះបានធ្វើឱ្យម្ចាស់សហគ្រាស រោងចក្រនៅប្រទេសថៃមិនសប្បាយចិត្តឡើយ ពីព្រោះពួកគេមិនអាចរកកម្លាំងមកជំនួសវិញបានទាន់ពេលវេលាធ្វើឱ្យខាតបង់ការរកស៊ី។

ប្រការដែលគួរឱ្យកត់សម្គាល់បំផុតគឺថា នៅពេលដែលពលករកម្ពុជាយើងត្រូវបានអាជ្ញាធរថៃបណ្តេញត្រឡប់មកវិញ ពេលបញ្ជូនមកដល់ព្រំដែនរាជរដ្ឋាភិបាលកម្ពុជា អាជ្ញាធរដែនដី និងក្រុមការងារចុះមូលដ្ឋានរួមទាំងផ្នែកពាក់ព័ន្ធនានាបានចុះទៅជួយឧបត្ថម្ភដោយផ្ទាល់នូវគ្រឿងឧបភោគបរិភោគ មធ្យោបាយដឹកជញ្ជូន ការថែទាំសុខភាព សុវត្ថិភាព និងដឹកជញ្ជូនបងប្អូនទៅដល់ស្រុកភូមិកំណើត ។ ជួយព្យាបាល និងឧបត្ថម្ភដល់ពលករដែលមានជំងឺ ឬដែលជួបប្រទះនូវគ្រោះថ្នាក់នានា ព្រមទាំងអ្នកទទួលមរណភាពទៀតផង ។រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញសេចក្តីណែនាំឱ្យរដ្ឋបាលខេត្តជាប់ព្រំដែនត្រួតពិនិត្យការទទួលពលករខ្មែរដែលត្រឡប់មក ពីប្រទេសថៃស្របតាមគោលការណ៍ជំនាញ ត្រួតពិនិត្យណែ-នាំ និងសហការសម្របសម្រួលការរៀបចំកន្លែងស្នាក់នៅបណ្តោះអាសន្ន អាហារ ថ្នាំពេទ្យ ដើម្បីធានាបាននូវសុខភាព និងសុខុមាលភាពរបស់ពលករ ពិសេស ជនចាស់ជរា ស្ត្រី កុមារ និងអ្នកមានជំងឺ ។ក្នុងរយៈពេលនៃការបញ្ជូនពលករខ្មែរមកវិញនេះ ក្រៅពីការខិតខំ របស់រាជរដ្ឋាភិបាលក៏មានការចូលរួមយ៉ាងសកម្មពីមន្ត្រីគ្រប់លំដាប់ថ្នាក់ រួមទាំងអាជ្ញាធរថ្នាក់ក្រោមជាតិ និងសប្បុរសជន បណ្តាអង្គការមួយចំនួនក៏បានរួមឧបត្ថម្ភរំលែកទុក្ខលំបាករបស់ពលករយើងផងដែរ ។ អាជ្ញាធរគ្រប់មូលដ្ឋានដែលជាស្រុកកំណើតរបស់ពលករក៏បានទទួលឧបត្ថម្ភជួយទំនុកបម្រុងបានទាន់ពេលវេលានៅពេលដែលពលករយើងទៅដល់ ។

រាជរដ្ឋាភិបាលកម្ពុជាក៏បានបង្កលក្ខណសម្បត្តិងាយស្រួលឱ្យពលករមានការយល់ដឹងកាន់តែច្បាស់ពាក់ព័ន្ធ នឹងការធ្វើបែបបទឆ្លងដែនទៅប្រទេសជិតខាងដោយស្របច្បាប់ ហើយថែមទាំងបានចេញអនុក្រឹត្យក្នុងការផ្តល់លិខិតឆ្លងដែនជូនពលករខ្មែរដែលត្រូវទៅធ្វើការដោយស្របច្បាប់នៅបរទេសដោយជាបន្ទុករបស់រដ្ឋដែលត្រូវចំណាយថវិកាតែ ៤ ដុល្លារប៉ុណ្ណោះ។ ជាមួយគ្នានេះ ក្រសួងអប់រំយុវជន និងកីឡាបានណែនាំដល់គ្រប់គ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ត្រៀមទទួលសិស្សសម្រាប់បវេសនកាលឆ្នាំ ២០១៤-២០១៥ ឱ្យបានល្អ ពិសេសត្រូវបង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្សដែលមកពីគ្រួសារធ្វើមាតុភូមិនិវត្តន៍ពីប្រទេសថៃឱ្យបានចូលរៀន ឬបន្តការសិក្សាស្របតាមកម្រិតថ្នាក់ឱ្យបានគ្រប់ៗគ្នា ហើយក៏បានអំពាវនាវដល់សហគមន៍ អាជ្ញាធរដែនដី និងអ្នកពាក់ពន្ធ័នៅមូលដ្ឋានដើម្បីជួយឧបត្ថម្ភគាំទ្រជាសម្ភារៈសិក្សា សៀវភៅ និងសម្លៀកបំពាក់ដល់សិស្សទាំងនោះ ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់កម្លាំងសរុប មធ្យោបាយសរុប ក្នុងការដោះស្រាយសម្របសម្រួលធ្វើយ៉ាងណាឱ្យពលករយើងរួចផុតពីការលំបាក និងមានលទ្ធភាពក្នុងការបន្តជីវភាពរស់នៅឱ្យបានសមរម្យ ។គួរកត់សម្គាល់ថា ក្នុងពេលដែលពល-ករកំពុងតែប្រឈមនឹងហានិភ័យ ហើយរាជរដ្ឋាភិបាលកំពុងតែទទួលរ៉ាប់រងបន្ទុកដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរនេះ បែរជាគណបក្សប្រឆាំង និង

តទៅទំព័រទី ២៥

# ព្រះរាជពិធីដង្ហែ និងតម្កល់ព្រះបរមអដ្ឋិព្រះបរមរតនកោដ្ឋ





*ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** សម្តេចព្រះសង្ឃរាជទាំងពីរគណៈ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ឯកឧត្តម **សាយ ឈុំ** ព្រមទាំងឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិការដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល អង្គទូតនៃបណ្តាប្រទេសជាមិត្តប្រចាំនៅកម្ពុជា រាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីជាច្រើនរូប និមន្ត យាង និងអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់**ព្រះបរមអដ្ឋិ***





ព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់ព្រះបរមអដ្ឋិព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** ដែលមានរយៈពេល ៣ ថ្ងៃ បានប្រព្រឹត្តទៅដោយជោគជ័យ ។ យាង និងអញ្ជើញចូលរួមក្នុងព្រះរាជពិធីបុណ្យដ៏អធិក-



*ប្រជាជនចូលរួមក្នុងព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់**ព្រះបរមអដ្ឋិ***

អធមនេះមានព្រះរាជវត្តមានដ៏ខ្ពង់ខ្ពស់នៃព្រះករុណា **ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** សម្តេចព្រះសង្ឃរាជទាំងពីរគណៈ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាក្រកម្ពុជា ឯកឧត្តម **សាយ ឈុំ** អនុប្រធានទីមួយព្រឹទ្ធសភា ព្រមទាំងឯក-ឧត្តម លោកជំទាវ ជាសមាជិក សមាជិការដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋា-ភិបាល អង្គទូតនៃបណ្តាប្រទេសជាមិត្តប្រចាំនៅកម្ពុជា រាជវង្សានុវង្ស និងនាម៉ឺនសព្វមុខមន្ត្រីជាច្រើនរូប ។

ក្នុងរយៈពេល ៣ថ្ងៃនៃព្រះរាជពិធីបុណ្យនេះ ( ថ្ងៃទី ១០-១១ និង ១២ខែកក្កដា) នៅថ្ងៃទី១០ខែកក្កដាជាពិធីគោរព**ព្រះវិញ្ញាណក្ខន្ធ** ពិធីបង្សុកូល និងរាប់បាត្រនៅមុខព្រះបរមរាជវាំង ដែលរៀបចំចាត់ចែងដោយក្រសួងធម្មការនិងសាសនា ។ថ្ងៃទី១១ខែកក្កដា ព្រះរាជពិ-

ធីដង្ហែ និងតម្កល់ **ព្រះបរមអដ្ឋិ** តាំងនៅព្រះចេតិយនៃបរិវេណព្រះវិហារព្រះកែវមរកតសម្រាប់ប្រារព្ធព្រះរាជពិធីបុណ្យទៅតាមព្រះរាជប្បវេណីជាតិ និងពិធីសាសនា និងថ្ងៃ ១២ កក្កដា ជាថ្ងៃនៃការតម្កល់ **ព្រះបរមអដ្ឋិ** ។ ព្រឹក ថ្ងៃ យប់ មានកម្មវិធីសាសនា កម្មវិធីគោរពព្រះវិញ្ញាណក្ខន្ធ កម្មវិធីបាញ់កាំជ្រួចនិងមានកម្មវិធីបាញ់កាំភ្លើងធំនៅពេលដង្ហែ និងបញ្ចុះ **ព្រះបរមអដ្ឋិ** ។

សូមបញ្ជាក់ថា នៅថ្ងៃសុក្រ ១៥ កើត ខែអាសាឍ ឆ្នាំមមី ឆស័ក ព.ស២៥៥៨ត្រូវនឹងថ្ងៃទី១១ខែកក្កដាឆ្នាំ២០១៤ការរៀបចំក្បួនដង្ហែ **ព្រះបរមអដ្ឋិ**" **ព្រះបរមរតនកោដ្ឋ**"ដែលមានចម្ងាយផ្លូវប្រមាណ ៣២០០ ម៉ែត្រ បានប្រព្រឹត្តទៅដោយថ្មើរជើង ។ចំណុចចាប់ផ្តើមពីទ្វារជ័យ បត់ឆ្វេងតាមមហាវិថីសុធារស បត់ឆ្វេងតាមវិថីសម្តេចព្រះធម្មលិខិត អ៊ុក បត់ឆ្វេងតាមមហាវិថីព្រះនរោត្តម ព័ទ្ធខាងលិចវិមានឯករាជ្យ បត់ឆ្វេងតាមមហាវិថីសម្តេចព្រះសីហនុ បត់ឆ្វេងតាមមហាវិថីសម្តេចសុធារស និងចូលព្រះឧបោសថរតនារាមព្រះកែវមរកតតាមទ្វារធំខាងកើត។ ក្នុងព្រះរាជពិធីដង្ហែ **ព្រះអដ្ឋិព្រះបរមរតនកោដ្ឋ** នេះ មានប្រជាពលរដ្ឋ សិស្ស និស្សិត មន្ត្រីរាជការចូលរួមប្រមាណជាង ២ ម៉ឺននាក់ ដង្ហែទៅតម្កល់ក្នុងព្រះបរមចេតីយ៍នៃព្រះវិហារព្រះកែវមរកត ។

បន្ទាប់មក **ព្រះបរមអដ្ឋិព្រះបរមរតនកោដ្ឋ** ត្រូវបានបញ្ចុះក្នុងព្រះបរមចេតិយនៅម៉ោង ៦ ព្រឹកថ្ងៃសៅរ៍ ទី ១២ ខែកក្កដា ឆ្នាំ២០១៤ រួចរាល់នៅម៉ោងប្រមាណ ៨ និង ២២ នាទី ។ នៅព្រឹកនោះដែរ ពុទ្ធបរិស័ទ និងប្រជាពលរដ្ឋដែលបានចូលរួមបានរាប់បាត្រប្រគេនព្រះសង្ឃចំនួន ៣ ៦០០ អង្គ ដើម្បីឧទ្ទិសនូវមហាកុសលថ្វាយ **ព្រះបរមរតនកោដ្ឋ អង្គព្រះ មហាក្សត្រនិងសម្តេចព្រះវររាជមាតាជាតិខ្មែរ** រាជវង្សានុវង្ស ថ្នាក់ដឹកនាំកំពូលៗ នាម៉ឺនសព្វមុខមន្ត្រី បានបន្តប្រារព្ធព្រះរាជពិធីតាមព្រះរាជប្បវេណី និងព្រះពុទ្ធសាសនាជាកិច្ចបង្ហើយបុណ្យពីម៉ោង ១៧ ល្ងាច រហូតដល់ម៉ោង ២០ យប់ ។

ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មាននៅព្រឹកថ្ងៃទី ១២ កក្កដា ក្នុងឱកាសដែលឯកឧត្តមចូលរួមតម្កល់**ព្រះបរមអដ្ឋិ** ឯកឧត្តម **ចាំ សុ~**



ព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់**ព្រះបរមអដ្ឋិ**

**ជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញបានមានប្រសាសន៍ថា ព្រះរាជពិធីរយៈពេល ៣ ថ្ងៃនេះ បានប្រព្រឹត្តទៅដោយជោគជ័យជាពិសេស សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ មានលក្ខណៈល្អប្រសើរ ។

សូមរំឭកថា ព្រះករុណា **ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** "**ព្រះបរមរតនកោដ្ឋ**" បានយាងសោយព្រះទិវង្គតក្នុងព្រះជន្មាយុ ៩០ ព្រះវស្សា ដោយព្រះរោគាពាធកាលពីថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០១២នៅទីក្រុងប៉េកាំងប្រទេសចិន ។**ព្រះបរមសពព្រះបរមរតនកោដ្ឋ** ត្រូវបានដង្ហែមកកាន់ព្រះរាជាណាចក្រកម្ពុជាវិញតម្កល់ប្រារព្ធព្រះរាជពិធីកាន់មរណទុក្ខ និងព្រះរាជពិធីបុណ្យទៅតាមព្រះរាជប្បវេណីព្រះពុទ្ធសាសនា នៅក្នុងព្រះបរមរាជវាំងរហូតដល់ថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០១៣ ទើបប្រារព្ធពិធីដង្ហែទៅកាន់ព្រះមេរុ ដើម្បីតម្កល់ប្រារព្ធព្រះរាជពិធីថ្វាយព្រះភ្លើង។ ព្រះរាជពិធីថ្វាយព្រះភ្លើងបានប្រព្រឹត្តទៅនាល្ងាចថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០១៣ ហើយ "ព្រះរាជពិធីរើស **ព្រះអដ្ឋិ**" បានធ្វើឡើងនាព្រឹកថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០១៣ ។ **ព្រះកោដ្ឋ**ទាំងបីនៃ**ព្រះអដ្ឋិ**របស់ព្រះអង្គដែលមាន**ព្រះកោដិ**មាសចំនួន ២ និង **ព្រះកោដ្ឋ**ថ្មកែវចំនួន ១ ត្រូវបានធ្វើពិធីដង្ហែពីព្រះមេរុទៅតម្កល់ក្នុងព្រះរាជវាំងចាប់ពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០១៣។

**ព្រះមហាវីរក្សត្រ**" **ព្រះបរមរតនកោដ្ឋ**"បានសោយព្រះ





ប្រជាជនចូលរួមក្នុងព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់**ព្រះបរមអដ្ឋិ**




*ទិដ្ឋភាពទូទៅនៃព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់**ព្រះបរមអដ្ឋិ***

ទិវង្គតជិត ២ ឆ្នាំហើយ ប៉ុន្តែព្រះរាជកាយវិការ និងព្រះរាជបូជនីយកិច្ចរបស់ព្រះអង្គនៅតែជិតជាប់ក្នុងដួងចិត្តប្រជារាស្ត្រខ្មែរជាកូនចៅរបស់ព្រះអង្គជានិច្ចនិរន្តរ៍ ជាពិសេសការរំលឹកនូវស្នាព្រះហស្ថដ៏ច្រើនឥតគណនាដែលព្រះអង្គបានបំពេញព្រះរាជកិច្ចជាឧត្តមប្រយោជន៍ជូនប្រទេសជាតិ មាតុភូមិ និងប្រជាជនកម្ពុជា ដោយបានទាមទារឯករាជ្យពីអាណានិគមនិយមបារាំងបាននៅថ្ងៃទី ៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ។ ប្រជាជាតិទាំងមូលបានប្រសិទ្ធនាមព្រះអង្គថាជា **ព្រះបិតាឯករាជ្យជាតិខ្មែរ** ។ បន្ទាប់ពីបានទទួលឯករាជ្យ ព្រះអង្គបានកសាងមាតុភូមិកម្ពុជាក្រោមបាវចនា ជាតិ សាសនា ព្រះមហាក្សត្រ តាមមាគ៌ាសង្គមរាស្ត្រនិយម ។ នៅពេលនោះ សមិទ្ធផលយ៉ាងច្រើនគ្រប់វិស័យត្រូវបានបង្កើតឡើងនៅគ្រប់ទិសទី ដូចជា គ្រឹះស្ថានសិក្សាគ្រប់កម្រិត មន្ទីរពេទ្យ ផ្លូវថ្នល់ ស្ពាន ស្រះទឹក ប្រឡាយទឹក វត្តអារាម រោងចក្រ កំពង់ផែ និងអាកាសយានដ្ឋាន ជាដើម ។

រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានសម្រេចសាងសង់វិមាន និង**ព្រះបរមរូប "ព្រះបរមរតនកោដ្ឋ"** នៅសួនច្បារខាងកើតវិមានឯករាជ្យ ដើម្បីជានិមិត្តរូបនៃការដឹងព្រះគុណ និងការចងចាំជានិច្ចនូវព្រះរាជជីវប្រវត្តិព្រះរាជបូជនីយកិច្ច និងស្នាព្រះហស្ថដ៏ធំធេងរបស់ព្រះបាទ **សម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ** ចំពោះ



*ប្រជាជនចូលរួមក្នុងព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់**ព្រះបរមអដ្ឋិ***



*ព្រះបរមចេតីយតម្កល់ **ព្រះបរមអដ្ឋិ ព្រះបរមរតនកោដ្ឋ***

ជាតិមាតុភូមិ និងប្រជារាស្ត្រខ្មែរ ។ ក្នុងឱកាសនៃពិធីសម្ពោធវិមាន និងព្រះបរមរូបកាលពីព្រឹកថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៣ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងថា "**ព្រះបិតាជាតិរបស់យើង គឺជាព្រះបិតាជាតិជារៀងរហូត**" ។

ប្រការដ៏សំខាន់មួយទៀត ឆ្លងតាមព្រះរាជពិធីដង្ហែ និងតម្កល់ **ព្រះបរមអដ្ឋិ "ព្រះបរមរតនកោដ្ឋ"** នាពេលនេះ បានបង្ហាញអំពីអត្តសញ្ញាណវប្បធម៌ប្រពៃណីដ៏ឧត្តុង្គឧត្តមរបស់ប្រជាជាតិយើងដែលធ្លាប់មានអរិយធម៌ដ៏ខ្ពង់ខ្ពស់ល្បីល្បាញលើសកលលោក ។

នៅថ្ងៃទី ១៤ កក្កដា **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គបានសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជសារជូនសម្តេចតេជោ **ហ៊ុនសែន** សម្តែងនូវអំណរព្រះគុណជាអនេកប្បការ និងកតវេទិតាដ៏ជ្រាលជ្រៅជូនសម្តេចតេជោ ដែលបានចាត់ចែងរៀបចំព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់ **ព្រះបរមអដ្ឋិព្រះករុណាព្រះមហាវីរក្សត្រព្រះវររាជបិតាជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** ក្នុងរយៈពេលបីថ្ងៃប្រកបដោយលទ្ធផលល្អប្រសើរ សក្តិសមនឹងព្រះកិត្តិយស ព្រះកិត្តិនាមជា "**ព្រះមហាវីរក្សត្រ**" **ដ៏ឧត្តុង្គឧត្តមនៃប្រជាជាតិ និងប្រជារាស្ត្រកម្ពុជាយើង** ។/

# សម្តេចអគ្គមហាធម្មពោធិសាលប្រគេនទៀនព្រះវស្សាដល់ព្រះសង្ឃចំនួន ១២ វត្ត នៅរាជធានីភ្នំពេញ





*សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ក្នុងពិធីបុណ្យប្រគេនទៀនវស្សា និងទេយ្យទានដល់ព្រះសង្ឃ ដែលគង់ចាំព្រះវស្សានៅវត្តចំនួន ១២ នៅរាជធានីភ្នំពេញ*

កាលពីថ្ងៃទី ៣ កក្កដា សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបុត្រាបុត្រី ចៅប្រុស ចៅស្រី និងមន្ត្រីរាជការជាច្រើននាក់បានអញ្ជើញចូលរួមក្នុងពិធីបុណ្យ ប្រគេនទៀនវស្សា និងទេយ្យទានដល់ព្រះសង្ឃ ដែលគង់ចាំព្រះវស្សានៅវត្តចំនួន ១២ នៅរាជធានីភ្នំពេញ ព្រមទាំងឧទ្ទិសនូវមហាកុសលដែលកើតមានដោយសទ្ធាជ្រះថ្លារបស់សម្តេចប្រធាន និងក្រុមគ្រួសារនៅថ្ងៃនោះ ចំពោះវិញ្ញាណក្ខន្ធលោកជំទាវ **ញៀម សឿន ជា ស៊ីម** ដែលបានទទួលមរណភាពទៅកាលពី ៥ ឆ្នាំមុននេះ និងឧទ្ទិសកុសលជូនដល់អ្នកមានគុណ មានមាតា បិតា គ្រូឧបជ្ឈាយាចារ្យ និងញាតិការទាំង៧សន្តានដែលបានចែកឋានទៅ។

គួររំឭកថា តាមទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរយើង បុណ្យចូលព្រះវស្សាដែលត្រូវបានពុទ្ធបរិស័ទខ្មែរយើងប្រារព្ធធ្វើជារៀងរាល់ឆ្នាំមានរយៈពេល ៣ ខែ ដោយចាប់ផ្តើមពីថ្ងៃ ១ រោច ខែអាសាធ ហើយបញ្ចប់វិញនៅថ្ងៃ ១៥ កើត ខែអស្សុជ។ ក្នុងអំឡុងពេលចូលព្រះវស្សានេះ ព្រះសង្ឃមិនអាចនិមន្តចេញទៅបិណ្ឌបាតនៅខាងក្រៅបានទេ គឺគង់នៅចាំព្រះវស្សាក្នុងទីវត្តអារាមនីមួយៗរហូតដល់ចប់តាមកាលកំណត់។ ពុទ្ធបរិស័ទដែលមានសទ្ធាជ្រះថ្លាក្នុងការរួមចំណែកប្រគេននូវទេយ្យទានដល់ព្រះសង្ឃក្នុងពិធីបុណ្យចាំព្រះវស្សានឹងទទួលបានអានិសង្សផលបុណ្យកើតមានដល់ក្រុមគ្រួសារ ។

ទេយ្យទានដែលសម្តេចអគ្គមហាធម្មពោធិសាលបានប្រគេនព្រះសង្ឃគង់នៅក្នុងវត្តទាំង ១២ នៅរាជធានីភ្នំពេញ រួមមាន ទៀនព្រះវស្សា បច្ច័យជាថវិកា អង្ករ ផ្លែឈើ មី ទឹកដោះគោ ត្រីខ ស្ករស ទឹកក្រូច ទឹកសុទ្ធ និងសម្ភារៈមួយចំនួនទៀត ។/




សូមគោរពឯកឧត្តម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព
សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្តីប្រជាជន
ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្តល់ទស្សនៈ ឬ មតិផ្សេងៗ

# សម្ដេចតេជោ ហ៊ុន សែន សម្ពោធស្ពានអាកាសស្ទឹងមានជ័យ

## ✵ សេវាដឹកជញ្ជូនសាធារណៈរបស់រាជធានីនឹងមិនយកថ្លៃពីព្រះសង្ឃ ជនពិការ និងសិស្ស

## ✵ ស្ពានអាកាសថ្មីតិចណាស់ នឹងបើកការដ្ឋានសាងសង់នៅពេលដ៏ខ្លីខាងមុខ

ស្ពានអាកាសស្ទឹងមានជ័យ ឬហៅម្យ៉ាងទៀតថា ជាស្ពានមេអំបៅ ត្រដាងស្លាប ត្រូវបានប្រារព្ធពិធីសម្ពោធជាផ្លូវការកាលពីព្រឹកថ្ងៃទី៣១ខែកក្កដា ឆ្នាំ ២០១៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន**។ សមិទ្ធថ្មីមួយនេះនឹងរួមចំណែករំដោះការធ្វើចរាចរណ៍របស់ប្រជាពលរដ្ឋដែលធ្លាប់តែកកស្ទះនៅតំបន់ដ៏មមាញឹកនោះ។

នៅក្នុងរបាយការណ៍របស់ឯកឧត្ដម **ប៉ា សុជាតិវង្ស** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញបានថ្លែងថា សមិទ្ធផលទាំងអស់នេះបានកើតចេញពីមនុញ្ញផលនៃសុខសន្តិភាព ស្ថិរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិតរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន**។

មានប្រសាសន៍ក្នុងឱកាសនោះសម្ដេចតេជោបានរំឭកថា យើងបានចាប់ផ្ដើមកសាងទីក្រុងភ្នំពេញដំបូងបន្ទាប់ពីរំដោះចេញពីរបបប្រល័យពូជសាសន៍ឆ្នាំ១៩៧៩ ក្នុងស្ថានភាពដែលទីក្រុងភ្នំពេញមានផ្ទះអត់មនុស្សនៅ មានផ្លូវអត់មនុស្សដើរ ស្ថានភាពទីក្រុងភ្នំពេញនាពេលនោះគឺជាទីក្រុងខ្មោចហើយគួរឱ្យខ្លាចជាងនៅព្រៃទៀត។កាលៈទេសៈនោះយើងមិនដែលឮសូរពាក្យថា គ្រោះថ្នាក់ចរាចរស្លាប់មនុស្សនោះទេ សូម្បីតែផ្លូវនៅទីកន្លែងហ្នឹងអាចដេកបានដោយគ្មានការរំខានដល់អ្នកណាទាំងអស់។ អត់មានឡានបុកទេ ព្រោះវាអត់មានឡានបើកកាលពីពេលនោះ ប៉ុន្តែឥឡូវនេះជាមួយនឹងវត្តមាននៃប្រជាពលរដ្ឋជាង ១ លាននាក់ អ្នករកការងារធ្វើ និងអ្នកឆ្លងកាត់ដទៃទៀត ក្នុងមួយថ្ងៃប្រហាក់ប្រហែលមិនតិចជាង ២ លាននាក់ទេ។ វត្តមានប្រជាពលរដ្ឋកាន់តែច្រើនឡើង ការកសាងបុរីថ្មីៗមានជាង ៧៤ បុរី ផ្ទះសម្បែងត្រូវបានកសាងច្រើនណាស់។ ទំហំផ្ទៃដីនៅទីក្រុងភ្នំពេញពីមុនមានជាង ៣០០ គីឡូម៉ែត្រការ៉េ ឥឡូវជិត ៧០០ គីឡូម៉ែត្រការ៉េ។ គឺបានរីកធំជាងពីរដង។

សម្ដេចបានបន្តទៀតថា ក្នុងពេលជាមួយគ្នានេះ វត្តមាននៃរថយន្តប្រមាណជាង ៣០ ម៉ឺនគ្រឿង និងម៉ូតូប្រមាណជាង ១ លានគ្រឿង បានបង្កើតឡើងនៅស្ថានភាពដ៏លំបាកសម្រាប់យើងដោះស្រាយបញ្ហាចរាចរណ៍ក្នុងទីក្រុង ហើយបន្ថែមទៅដោយបទល្មើសនៃការបើកបរមិនគោរពច្បាប់ចរាចរណ៍ បើកដោយផ្ទុកគ្រឿងស្រវឹង...នេះជាបញ្ហាក្រៅពីរឿងការកកស្ទះដោយសារមធ្យោបាយកាន់តែច្រើនទៅៗនោះ។

ទាក់ទងនឹងការដឹកជញ្ជូនសាធារណៈ សម្ដេចមានប្រសាសន៍ថាសម្ដេចបានណែនាំឱ្យបង្កើតរួចហើយនូវរដ្ឋាករដឹកជញ្ជូនសាធារណៈរបស់ក្រុងដោយបានអនុញ្ញាតឱ្យនាំចូលរួចមកហើយនូវរថយន្តក្រុងចំនួន ៤៣ គ្រឿង។ បើក្រុមហ៊ុនមួយមកសាកល្បងហើយទៅវិញបាត់ៗ ដូចនេះយើងត្រូវតែ




*សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន***
*និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន***
*អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធស្ពានអាកាសស្ទឹងមានជ័យ*

វិនិយោគខ្លួនឯង។ សម្ដេចក៏បានប្រាប់ទៅឯកឧត្ដម **ប៉ា សុជាតិវង្ស** អភិបាលរាជធានីភ្នំពេញថា ត្រូវធ្វើឱ្យបានជោគជ័យ ព្រោះរឿងនេះមិនជោគជ័យ តាំងតែពីជំនាន់ឯកឧត្ដម **កែប ជុតិមា** ចូលដល់ឯកឧត្ដម **ប៉ា សុជាតិវង្ស** ជាងមួយឆ្នាំហើយនៅមិនជោគជ័យទៀត។ ឥឡូវត្រូវធ្វើឱ្យជោគជ័យ បង្កើតរដ្ឋាករដឹកជញ្ជូនសាធារណៈ។ រាជរដ្ឋាភិបាលគាំទ្រការនាំចូលរថយន្តដឹកជញ្ជូនសម្រាប់សេវាដឹកជញ្ជូនសាធារណៈដោយអាករជាបន្ទុករបស់រដ្ឋ។ រដ្ឋមិនយកពន្ធលើរថយន្តនេះទេ។ នេះជាការគាំទ្រផ្នែករដ្ឋឧបត្ថម្ភដល់សាលាក្រុងតាមរយៈការនាំចូលរថយន្តដឹកជញ្ជូនដោយមិនយកពន្ធ។ ប៉ុន្តែសម្ដេចរំឭកថា គឺឱ្យតែឡានដឹកជញ្ជូនទេ តិចលោចាប់ផ្ដើមរាលដាលថាថ្នាក់ដឹកនាំរដ្ឋាករដឹកជញ្ជូនសូមនាំចូលដោយរួចពន្ធនូវរថយន្តដើម្បីជិះបម្រើការសុទ្ធតែម៉ែសឺដេស ឡិចស៊ុស... គឺមិនឱ្យទេ គឺឱ្យតែរថយន្តដឹកអ្នកដំណើរប៉ុណ្ណោះ។

សម្ដេចបន្តថា រឿងសេវាដឹកជញ្ជូននេះវាអត់អស់ច្រើនប៉ុន្មានទេ។ យកក្រុងចិញ្ចឹមក្រុង។ យកផលចំណេញ ពីកន្លែងណាមួយយកមកប៉ះប៉ូវឧបត្ថម្ភទុនខ្លះទៅ។ រដ្ឋាភិបាលធ្លាប់ឧបត្ថម្ភទុនសម្រាប់អគ្គិសនីដើម្បីប្រជាពលរដ្ឋនៅភ្នំពេញ ហើយរឿងសេវាដឹកជញ្ជូននេះវាអត់អស់ច្រើនប៉ុន្មានទេ បើសិនជាខាតយើងអាចយកផលចំណេញពីកន្លែងផ្សេងមកជួយបំពេញខាតឱ្យសេវាដឹកជញ្ជូននេះ។

សម្ដេចតេជោក៏បានបញ្ជាក់ថា ក្នុងការដឹកជញ្ជូនសាធារណៈនេះគឺមិនយកថ្លៃពីជនពិការ សិស្ស និស្សិត និងព្រះសង្ឃទេ។ ការផ្ដល់សេវាដូច្នេះដើម្បីកាត់បន្ថយនូវចំនួនរថយន្តឬម៉ូតូដែលកូនសិស្សជិះទៅសាលាឬឪពុកម្ដាយជូនទៅសាលា ហើយក៏ធានាសុវត្ថិភាពសិស្សានុសិស្សដែលជាកូនចៅរបស់ប្រជាពលរដ្ឋផងដែរ។ បញ្ហានេះត្រូវរៀបចំសៀវភៅបន្ទុកឱ្យ





សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ផ្ដល់អនុសាសន៍ក្នុងពិធីសម្ពោធស្ពានអាកាសស្ទឹងមានជ័យ

ច្បាស់លាស់ ។ រៀបចំជាក្របខណ្ឌគោលនយោបាយមួយនៃការលើកលែងការបង់ថ្លៃដល់ជនពិការ ព្រះសង្ឃនិងសិស្ស ។ ត្រូវធ្វើឱ្យឈ្នះលើរឿងនេះ ។

ជាមួយគ្នានោះ សម្ដេចបានណែនាំឱ្យរដ្ឋាករជីកជញ្ជូន “កុំដេកផ្សំដួល រមួលផ្សំគ្រេច” ពេលណាក៏ខាត។ ត្រូវមើលឱ្យល្អទាក់ទងលើការគ្រប់គ្រង ។ សម្ដេចគិតថា IMF ក្ដី ធនាគារពិភពលោកក្ដីនឹងមិនផ្ដល់មតិថាធ្វើដូច្នេះវាខុសពីគោលការណ៍នៃសេដ្ឋកិច្ចផ្សារនោះទេ ។ ធ្វើដូច្នេះ គឺដោយសារតែឯកជនធ្វើមិនជោគជ័យ រួចសេវាឡានក្រុងនៅតែមិនដំណើរការ ហើយប្រជាពលរដ្ឋក៏ចេះតែកកស្ទះទៅ ។ សម្ដេចបន្តថា ពិតមែនតែរដ្ឋខាតមួយចំនួន តែប្រជាពលរដ្ឋគាត់ចំណេញក្នុងការធ្វើដំណើរ ហើយសុវត្ថិភាពរបស់អ្នកពិការ សិស្ស ដែលធ្វើដំណើរតាមផ្លូវនឹងត្រូវបានដោះស្រាយ ។

សម្ដេចតេជោបានណែនាំឱ្យរៀបចំក្រោមស្ពានអាកាសស្ទឹងមានជ័យឱ្យក្លាយជាកន្លែងកំសាន្ត ហើយវិធីដោះស្រាយបញ្ហាកន្លែងនេះបានច្រើនរឿងតាមរយៈនៃការរៀបចំគម្របលូលើប្រឡាយទឹកស្អុយ ។ ធ្វើបែបនេះវានឹងកាត់បន្ថយក្លិនស្អុយជះដល់ប្រជាពលរដ្ឋ ប្រែក្លាយតំបន់នោះឱ្យទៅជាតំបន់សម្រាប់ប្រជាពលរដ្ឋហាត់ប្រាណ ។ ព្រោះឥឡូវប្រជាពលរដ្ឋត្រូវការហាត់ប្រាណ អ្នកស្ទឹងមានជ័យមិនចាំបាច់ទៅដល់មាត់ទន្លេហាត់ប្រាណទេ ព្រោះអាចហាត់នៅទីនេះបាន ។ ប៉ុន្តែសម្ដេចបានបញ្ជាក់ថា សូមមេត្តាកុំយកក្រោមស្ពានធ្វើជាផ្ទះរួចហើយប្រើទ្រឹស្ដី “ឈ្នះបានដីចាញ់បានលុយ” ហើយទៅប្ដឹងអង្គការបរទេស ។ សូមនាំគ្នាទៅថតកន្លែងហ្នឹងទុកឱ្យហើយដើម្បីថ្ងៃក្រោយនៅពេលមានការតវ៉ាបញ្ចាំងឱ្យមើល ។ កន្លែងហាត់ប្រាណនេះត្រូវធ្វើឱ្យស្អាត ធ្វើឱ្យទៅជាតំបន់ទៅហាត់ប្រាណមានក្លិនផ្កាវិញ ហើយសូមមេត្តាកុំនាំគ្នាទៅធ្វើផ្ទះ ដល់ធ្វើផ្ទះរួចហើយអាងតែមានស្ថានទូតបរទេស មានយូអិន មានអឺយូ (EU) និងមានស្ថានទូតដទៃទៀតទៅដាក់ញត្តិថាខ្លួននៅយូរហើយ ឥឡូវអាជ្ញាធរបណ្ដេញចេញ ។

ជាមួយគ្នានោះ សម្ដេចតេជោ **ហ៊ុន សែន** ក៏បានប្រកាសថា ស្ពានអាកាស និងផ្លូវក្រោមដីតិចណូ នឹងចាប់ផ្ដើមការសាងសង់ដែលនឹងត្រូវចំណាយទុនប្រមាណជាង ១៤ លានដុល្លារ បន្ទាប់ពីស្ពានអាកាសស្ទឹងមាន-ជ័យ ។ គឺជាស្ពានអាកាសទី ៤ (ស្ពានអាកាសតិចណូ) ត្រូវចាប់ផ្ដើមដែលមានទាំងស្ពានអាកាសផង និងក្រោមដីផង ។ អ្នកដែលស្រួលគឺអ្នកដែលនៅខាងទួលគោក ។ ប៉ុន្តែមិនមែនសំខាន់សម្រាប់តែអ្នកទួលគោកទេ គឺសំខាន់សម្រាប់ប្រជាពលរដ្ឋទាំងអស់ ។ ជាសមិទ្ធផលមួយទៀតដើម្បីដោះស្រាយបញ្ហាចរាចរណ៍នៅក្នុងទីក្រុងរបស់យើង ។ ដោយឡែកស្ពានឆ្លងកាត់ទន្លេបាសាក់នៅក្រុងតាខ្មៅក៏នឹងត្រូវសាងសង់រួចក្នុងពេលឆាប់ៗនេះ ដែលជួយកាត់បន្ថយការធ្វើដំណើរឆ្លងកាត់របស់រថយន្តធំៗក្នុងក្រុង ។

ប្រមុខរាជរដ្ឋាភិបាលបានឆ្លៀតឱកាសនោះអំពាវនាវទៅកាន់ប្រជា-ពលរដ្ឋដែលរស់នៅតាមដងទន្លេមេគង្គ ដងទន្លេសាប និងតាមកន្លែងដទៃទៀតអំពីការត្រៀមរៀបចំខ្លួន និងប្រុងប្រយ័ត្នពីទឹកជំនន់ ព្រោះថាសម្ដេចតេជោបានបញ្ជាក់ថា គិតត្រឹមព្រឹកថ្ងៃទី ៣១ ខែកក្កដា ទឹកនៅស្ទឹងត្រែងមានកម្ពស់រហូតដល់ ១០ ម៉ែត្រ ក្នុងពេលដែល ១០,៧០ ម៉ែត្រ ត្រូវប្រកាសអាសន្ន ។ នៅថ្ងៃទី ១ ខែសីហា កម្រិតទឹកនេះនឹងឡើងដល់ទៅ ១០,៦៥ ម៉ែត្រ គឺនៅសល់តែបន្តិចដល់កម្រិតប្រកាសអាសន្ន ហើយដល់ថ្ងៃទី ២ ខែសីហា នឹងអាចឡើងទៅដល់ ១០,៨៥ ម៉ែត្រ លើសកម្រិតប្រកាសអាសន្នហើយ ។ នៅក្រចេះកម្រិតប្រកាសអាសន្ន ២២ ម៉ែត្រ ហើយនៅថ្ងៃទី ២ ខែសីហា ទឹកនឹងឡើងដល់កម្ពស់ ២១,៩៥ ម៉ែត្រ ។ កម្រិតកម្ពស់ទឹកជំនន់បានកើនឡើងជិតដល់កម្រិតត្រូវប្រកាសអាសន្ន ហើយស្ទើរតែគ្រប់ខេត្តនៅតាមដងទន្លេមេគង្គ ។ អាជ្ញាធរតាមដងទន្លេមេគង្គ ទន្លេបាសាក់ ទន្លេសាប ត្រូវតែមានការប្រុងប្រយ័ត្នត្រៀមជម្លៀសប្រជាពលរដ្ឋក្នុងករណីចាំបាច់ ។ ជាមួយគ្នានោះដែរជំនន់ទឹកភ្លៀងនៅតាមតំបន់មួយចំនួន ដូចជានៅស្ទឹងត្រែង កំពង់ធំ ស្ទឹងពោធិ៍សាត់ និងស្ទឹងដទៃៗទៀតក៏ត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ព្រោះរដូវនេះជារដូវដែលមានការប្រុងប្រយ័ត្នហើយ ។

តទៅទំព័រទី ១២

# ឯកឧត្តម សាយ ឈុំ អនុប្រធានទី ១ ព្រឹទ្ធសភា ទទួលជួបសវនាការជាមួយ ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់





*ឯកឧត្តម **សាយ ឈុំ** ទទួលជួបសវនាការជាមួយឯកឧត្តម Baron von Marscal*

នាព្រឹកថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០១៥ ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម Baron von Marscall ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារនៅវិមានព្រឹទ្ធសភា ។

ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធសភា បានថ្លែងអំណរគុណដល់រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក៏ដូចជាប្រជាជនអាល្លឺម៉ង់ ដែលបានជួយគាំទ្រដល់ប្រទេសកម្ពុជាជាច្រើន តាមរយៈអង្គការសង្គមស៊ីវិលផ្សេងៗ ជាពិសេសកិច្ចសហប្រតិបត្តិការដ៏ល្អរបស់ខុនរ៉ាដអាឌិនណៅអ៊ែរ ដែលបានជួយដល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងលើវិស័យនានាជាច្រើនក្នុងការកំណែទម្រង់រដ្ឋបាលវិមជ្ឈការ ការពង្រឹងគណបក្សនយោបាយ ការអប់រំ និងអភិវឌ្ឍនច្បាប់ ព្រមទាំងវិស័យព័ត៌មានផងដែរ ។

ឯកឧត្តម Baron von Marschall ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ បានសម្ដែងការអបអរសាទរចំពោះកិច្ចពិភាក្សាបញ្ចប់ភាពតានតឹងនយោបាយនៅអំឡុងក្រោយការបោះឆ្នោតនាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣កន្លងមក ។ ឯកឧត្តមក៏បានលើកឡើងថានឹងបន្តពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែល្អរវាងប្រទេសទាំងពីរ ។ រដ្ឋាភិបាល ប្រជាជនសហព័ន្ធអាល្លឺម៉ង់ និងតាមរយៈមូលនិធិខុនរ៉ាដអាឌិនណៅអ៊ែរនឹងបន្តជួយគាំទ្រដល់កម្ពុជាបន្តទៀត ។

ជាការឆ្លើយតប ឯកឧត្តម **សាយ ឈុំ** អនុប្រធានទី ១ ព្រឹទ្ធសភា បានថ្លែងអំណរគុណ និងអបអរសាទរចំពោះប្រសាសន៍ដែលបានលើកឡើងរបស់ឯកឧត្តមឯកអគ្គរដ្ឋទូត ព្រមទាំងខិតខំពង្រឹងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការដ៏ល្អនេះថែមទៀត ។/

តមកពីទំព័រទី ១១

គួរបញ្ជាក់ថា ស្ពានអាកាសស្ទឹងមានជ័យ គឺជាស្ពានអាកាសទី ៣ នៅរាជធានីភ្នំពេញ បន្ទាប់ពីស្ពានអាកាសក្បាលថ្នល់ដែលសាងសង់រួច និងសម្ពោធកាលពីថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ២០១០ និងស្ពានអាកាស ៧ មករា ដែលបានសម្ពោធឱ្យប្រើប្រាស់កាលពីថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១១ កន្លងមកនេះ ។ យោងតាមកិច្ចសន្យា ស្ពានអាកាសស្ទឹងមានជ័យ គឺត្រូវប្រើរយៈពេល ២៨ ខែ ដើម្បីសាងសង់ដោយចាប់ផ្ដើមពីថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១២ ហើយគ្រោងបញ្ចប់នៅថ្ងៃទី ២៦ ខែមីនា ឆ្នាំ ២០១៥ ប៉ុន្តែជាក់ស្ដែងដោយមានកិច្ចខិតខំប្រឹងប្រែងក្នុងការស្ថាបនាទាំងថ្ងៃទាំងយប់ ធ្វើឱ្យការសាងសង់នេះ ប្រើរយៈពេលត្រឹមតែ ២០ ខែប៉ុណ្ណោះ ដោយចំណាយថវិកាសាងសង់សរុបចំនួន ១៨ ៩៧៦ ៦៧៨ ដុល្លារអាមេរិក ជាកញ្ចប់ថវិកាដែលបានមកពីការវិនិយោគដីជ្រោយចង្វាររបស់ក្រុមហ៊ុនវិនិយោគទុនអាណិកជនកម្ពុជា (OCIC) ។

ស្ពានអាកាសស្ទឹងមានជ័យសង់ឡើងជា ៣ ដំណាក់កាល ដោយមានស្ពានចំនួន ៥ ខ្សែ ។ មួយខ្សែគឺសង់ផ្លូវនៅក្រោមដីត្រង់ចំណុចស្តុបស្ទឹងមានជ័យ មានបណ្ដោយ ២៦៦ ម៉ែត្រ ទទឹងពី ៨ ម៉ែត្រ ទៅ ១០ ម៉ែត្រ ដោយបានចាក់អ៊ុតកៅស៊ូរួចជាស្រេច រួមនឹងការបំពាក់ម៉ូទ័រសម្រាប់បូមទឹកចេញផងដែរ ។ ២ ខ្សែទៀត សាងសង់ស្ពាន អាកាសលើកំណាត់ផ្លូវមុនីរ៉េត ។ ចំណែកស្ពានអាកាស ២ ខ្សែផ្សេងទៀត សាងសង់ឡើងដោយបំបែកខ្នែងចេញពីស្ពានអាកាសធំលើប្រឡាយស្ទឹងមានជ័យ ។

សម្ដេចតេជោនាយករដ្ឋមន្ត្រី និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ដែលអមដំណើរដោយមន្ត្រីអ្នកមុខ អ្នកការ និងមានការចូលរួមពីប្រជាពលរដ្ឋយ៉ាងច្រើនកុះករនោះ មុននឹងអញ្ជើញកាត់ខ្សែបូដើម្បីជានិមិត្តរូបនៃពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការនូវស្ពានអាកាសស្ទឹងមានជ័យ សម្ដេចបានផ្ដល់កិត្តិយសបំពាក់មេដាយជូនថ្នាក់ដឹកនាំរាជធានី និងថ្នាក់ដឹកនាំក្រុមហ៊ុនសាងសង់ផងដែរ ។/

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី៨ខែកក្កដា ឆ្នាំ២០១៤ ឯកឧត្តម **ស ខេង** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញសម្ពោធអគារសិក្សាថ្មី ១ ខ្នង មាន ៦ បន្ទប់ នៅសាលាបឋមសិក្សាពង្រ ស្ថិតក្នុងភូមិពង្រ ឃុំពង្រ ស្រុកចុងកាល់ ខេត្តឧត្ដរមានជ័យ ។ ក្នុងពិធីនេះឯកឧត្តមបានរំលឹកឱ្យចូលរួមថែរក្សាសមិទ្ធិនេះឱ្យបានល្អ ។



*ថ្ងៃទី ១៨ ដល់ ២០ ខែកក្កដា ឆ្នាំ ២០១៤ ឯកឧត្តមបណ្ឌិត* ***ឃួន ញ៉ឹល*** *សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ប្រធានក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តកំពង់ធំ អនុប្រធានទី ១ រដ្ឋសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សស្រុកបារាយណ៍ ។ កិច្ចប្រជុំបានធ្វើការចាត់តាំង និងកែសម្រួលសមាសភាពក្រុមការងារចុះជួយឃុំទាំង ១៨ និងផ្សព្វផ្សាយពីសភាពការណ៍ដែលបានកើតឡើងនៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃ ១៥ កក្កដា។ នៅរសៀលថ្ងៃដដែល ឯកឧត្តមបណ្ឌិតបានស្ដាប់របាយការណ៍របស់ លោក ជូ សំអាន ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តកំពង់ធំទើបតែងតាំងថ្មីដែលបានដឹកនាំគណៈប្រតិភូចូលជួបសម្ដែងការគួរសម និងសុំគោលការណ៍អនុសាសន៍ដឹកនាំអនុវត្តការងារពីឯកឧត្តមបណ្ឌិត ។ ឯកឧត្តមបណ្ឌិត* ***ឃួន ញ៉ឹល*** *ក៏បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំក្រុមការងារថ្នាក់កណ្ដាលចុះជួយខេត្តកំពង់ធំ ដើម្បីផ្សព្វផ្សាយសេចក្ដីសម្រេចចិត្តស្ដីពីការចាត់តាំងនិងកែសម្រួលសមាសភាពក្រុមការងារចុះជួយស្រុក-ក្រុងទាំង៨និងផ្សព្វផ្សាយពីសភាពការណ៍ដែលបានកើតឡើងនៅទីលានប្រជាធិបតេយ្យកាលពីថ្ងៃ ១៥ កក្កដា កន្លងទៅ ។ គួរបញ្ជាក់ថាក្នុងខែកក្កដា ឆ្នាំ ២០១៤ នេះ ឯកឧត្តមបណ្ឌិត* ***ឃួន ញ៉ឹល*** *បានចំណាយថវិកាសម្រាប់ប្រើប្រាស់លើការងារបក្សសរុបចំនួន ៥៤០៧ ដុល្លារអាមេរិក ។*







ថ្ងៃទី១៣ខែកក្កដាឆ្នាំ២០១៤លោកជំទាវ **ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងការអភិវឌ្ឍ បានអញ្ជើញជាអធិបតីក្នុងពិធីពិសាអាហារសាមគ្គីជាមួយលោកជំទាវ **ឡេវៀង មីហ៊ាំ** អតីតអនុ ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងជាប្រធានមូលនិធីអាហារូបករណ៍ វ៉ីអា យីញ ។ ក្នុងឱកាសនោះ លោកជំទាវ **ម៉ែន សំអន** បានសម្ដែងនូវការគាំទ្រចំពោះសកម្មភាពមនុស្សធម៌របស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តវៀតណាមដែលដឹកនាំដោយលោកជំទាវ **ឡេវៀង មីហ៊ាំ** ដែលបានចូលរួមក្នុងសកម្មភាពមនុស្សធម៌ជាមួយសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងការអភិវឌ្ឍដែលជាក់ស្ដែងកន្លងមក ក៏ដូចនាពេលថ្មីៗនេះ ក្រុមគ្រូពេទ្យស្ម័គ្រចិត្តវៀតណាមបានចុះមកពិនិត្យ និងព្យាបាលជំងឺ និងបានផ្ដល់អំណោយមនុស្សធម៌ មានសម្លៀកបំពាក់ ស្បែកជើង សៀវភៅ ខ្មៅដៃ កាតាប ដល់កុមារកំព្រា និងដល់ប្រជាពលរដ្ឋក្រីក្រកម្ពុជា ប្រមាណ ២០០០ នាក់ មកពីខេត្តចំនួន ៣ គឺខេត្តកណ្ដាល ខេត្តតាកែវ និងខេត្តព្រៃវែង ។



*ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៤ ឯកឧត្តម* ***ទេព ងន*** *អនុប្រធានទី ២ ព្រឹទ្ធសភា សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល បានអញ្ជើញចូលរួមជាកត្តិយសក្នុងពិធីបុណ្យរុក្ខទិវា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះករុណាព្រះបាទ* ***សម្ដេចព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅភូមិកណ្ដឹងធំ ឃុំកណ្ដឹង ស្រុកបាទី ខេត្តតាកែវ ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



*ថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០១៤ លោកជំទាវ **ឃួន សុដារី** អនុប្រធានទី២ នៃរដ្ឋសភា តំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយស្រុកលើកដែក ខេត្តកណ្តាល អមដំណើរដោយ ឯកឧត្តម លោកជំទាវ ជាទីប្រឹក្សា នាយកខុទ្ទកាល័យ មន្ត្រីខុទ្ទកាល័យ និងថ្នាក់ដឹកនាំ មន្ត្រី រាជការ ក្រសួងស្ថាប័ននានា បាននាំយកទៀនព្រះវស្សាទៅប្រគេនថ្វាយព្រះសង្ឃគង់ចាំព្រះវស្សាក្នុងពុទ្ធសីមាចំនួន ៧ វត្ត ស្ថិតក្នុងស្រុកលើកដែក ខេត្តកណ្តាល ។ ទ័យ្យទានដែលបានវេរប្រគេនព្រះសង្ឃ មានទៀនព្រះវស្សា អង្ករ ប្រេងម៉ាស៊ុត ប្រេងឆា ត្រីខកំប៉ុង ទឹកផ្លែឈើ ទឹកក្រូច ទឹកសុទ្ធ ទឹកត្រី ទឹកស៊ីអ៊ីវ មី ម្សៅសាប៊ូ ធូបវែង សៀវភៅសរសេរ ប្រគេនបច្ច័យថៅអធិការវត្ត និងព្រះសង្ឃគ្រប់អង្គសរុប ចំនួន ២ លាន ១ សែន ៥ ម៉ឺនរៀល និងបច្ច័យចូលបុណ្យសរុបចំនួន ១៥ លាន ៣ សែនរៀល ។ សរុបថវិកាក្នុងកម្មវិធីនេះអស់ថវិកាចំនួន ២៦,២១៨,៨០០ រៀល។*

ក្នុងខែកក្កដានេះដែរ ឯកឧត្តម **គាត ឈន់** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រីប្រចាំការ រួមជាមួយឯកឧត្តម **អូនព័ន្ធ មុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម **ជូ វិជិត្ត** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម **វេង សាខុន** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម បានចុះពិនិត្យសមិទ្ធផលនៃគម្រោងអភិវឌ្ឍន៍ធនធានទឹកក្រាំងពន្លៃ ស្ថិតនៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។ នេះជាគម្រោងជំនួយរបស់ប្រទេសកូរ៉េ ហើយក្នុងគម្រោងនេះមានវារីអគ្គីសនីខ្នាតតូច មួយផងដែរ។





ថ្ងៃទី១៣-១៤ ខែកក្កដាឆ្នាំ២០១៤ ឯកឧត្តម **ប៊ូ ថង** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តរតនគិរី និងលោកជំទាវ អមដំណើរដោយឯកឧត្តម **ប៊ូ ឡាំ** តំណាងរាស្ត្រខេត្តរតនគិរី ឯកឧត្តម **ម្លូង ប៉យ** ប្រធានក្រុមប្រឹក្សាខេត្ត ឯកឧត្តម **ថង សាវុន** អភិបាលខេត្ត និងឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ទីរជុំវិញខេត្ត បាននាំយកទេយ្យទាន និងទៀនវស្សាប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សានៅវត្តចំនួន១០ ក្នុងខេត្តរតនគិរី ដោយក្នុងមួយវត្តៗទទួលបាននូវទៀនវស្សាចំនួន ០១គូរ សាដក១ អង្ករ៥០គីឡូ មី១កេស ទឹកសុទ្ធ១កេស ទឹកក្រូច១កេស ទឹកស៊ីអ៊ីវ ១យួរ ត្រីខ១កេស ថវិកាចំនួន ៣០០,០០០រៀល ។

ឯកឧត្តម **ប៊ូ ថង** ព្រមទាំងគណៈប្រតិភូបានបានអញ្ជើញជាអធិបតីក្នុងពិធីអបអរសាទរបុណ្យរុក្ខាទិវា ៩ កក្កដា ២០១៤ និងបានប្រគល់កូនឈើចំនួន ៥០០ ដើម ផងដែរ ។

រសៀលថ្ងៃទី១៤ឯកឧត្តម **ប៊ូថង** បានបើកកិច្ចប្រជុំគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តរតនគិរី ដើម្បីពិភាក្សាជុំវិញការងារត្រួតពិនិត្យការចាត់តាំង និងកែសម្រួលសមាសភាពក្រុមការងារថ្នាក់ខេត្តចុះជួយស្រុកឃុំសង្កាត់នៅទីស្នាក់គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជាខេត្តរតនគិរី ។

*ថ្ងៃទី២៤ខែកក្កដាឯកឧត្តម**អ៊ឹម ឈុនលឹម**សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគូរូបនីយកម្ម និងសំណង់ បានអញ្ជើញចូលរួមបើកការដ្ឋានជីកស្រះទឹកទំហំ ១១ ហិកតា ជម្រៅ ៨ ម៉ែត្រ ជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ ចំនួន ៧៥៣ គ្រួសារ នៅភូមិជ្រៃសែនជ័យ ឃុំតាំងសំរោង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ ស្រះទឹកនេះជាអំណោយរបស់លោកឧកញ៉ា**ភួង អាន**សមាជិកព្រឹទ្ធសភានិងជាប្រធានក្រុមហ៊ុនអានកូ ។*



# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៥ខែកក្កដាឆ្នាំ២០១៤ឯកឧត្តម**ម៉ុក ម៉ារ៉េត** ប្រធានគណៈកម្មការទី ៣ នៃរដ្ឋសភា សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រួមដំណើរដោយឯកឧត្តម **ជា សុផារ៉ា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទបានដឹកនាំសមាជិកគណៈកម្មការអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខ ព្រមទាំងនាំយកអំណោយជូនកងទ័ព និងគ្រួសារកងទ័ពនៅខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ។ បន្ទាប់មក នៅថ្ងៃទី ១៦ ខែកក្កដា ឯកឧត្តម **ម៉ុក ម៉ារ៉េត** ព្រមទាំងប្រតិភូរួមដំណើរដោយឯកឧត្តម **សួស គង់** រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងឯកឧត្តម **ចាយ សាមិត្ត** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកតំបន់ការពារធម្មជាតិ បានអញ្ជើញចុះជួបសំណេះសំណាលសួរសុខទុក្ខប្រជាសហគមន៍តំបន់ធម្មជាតិ ៣ កន្លែង នៅខេត្តព្រះវិហារ ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ។





*ថ្ងៃទី ២៣ ខែកក្កដា ឯកឧត្តម **វង សូត** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានអញ្ជើញផ្តល់កង់ចំនួន ៤០០ គ្រឿង ដែលជាអំណោយរបស់អង្គការ កុគីសៃខេជេអូ ជូនដល់សិស្សានុសិស្សក្រីក្រមកពីសាលារៀនចំនួន ៧ នៅក្នុង ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ។*

ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៤ នៅវត្តឱង្ការ ឃុំទួល ព្រេជ ស្រុកអង្គស្នួល ខេត្តកណ្តាល ឯកឧត្តម **ម៉ម ប៊ុននាង** សមាជិកគណៈកម្មការ ទី៩ នៃព្រឹទ្ធសភា និងជាអនុប្រធានគណៈពង្រឹងខេត្តកណ្តាល បានអញ្ជើញចូលរួមដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តវៀតណាម មកពិនិត្យ និងព្យាបាលជំងឺដោយឥតគិតថ្លៃជូនដល់ប្រជាពលរដ្ឋចាស់ជរាទីទ័លក្រ ដែលមានជំងឺចំនួន ៥០០ នាក់ មកពីឃុំទួលព្រេជ ឃុំម្កាក់ និងឃុំសំរោងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ក្នុងនោះដែរ ឯកឧត្តម **ម៉ម ប៊ុននាង**ក៏បានសំដែងមតិសំណេះសំណាល និងផ្តល់ការណែនាំដ៏មានសារៈប្រយោជន៍ ក៏ដូចជាការចែករំលែកនូវបទពិសោធន៍ល្អៗជូនដល់ប្រជាពលរដ្ឋដែលមកពិនិត្យជំងឺឲ្យចេះអនាម័យខ្លួនប្រាណ និងថែទាំសុខភាព ដើម្បីជៀសវាងពីជំងឺឆ្លង និងជំងឺរាតត្បាតផ្សេងៗ។





*ថ្ងៃទី ៩ ខែកក្កដា ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានអញ្ជើញពិនិត្យស្ថានភាពរស់នៅជាក់ស្តែងរបស់បងប្អូនជនជាតិភាគតិចនៅខេត្តរតនគិរី និងចូលរួមជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង រវាងសហគមន៍តំបន់ការពារធម្មជាតិចំនួនប្រាំ ក្នុងភូមិអូតាបូកនៃឧទ្យានជាតិវីរៈជ័យ និងអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាននៅសណ្ឋាគាររតនៈស៊ីធី ខេត្តរតនគិរី ។*

# ព្រឹត្តិការណ៍សំខាន់ៗក្នុងខែ កក្កដា

-ថ្ងៃទី ១ កក្កដា សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងទិវាមច្ឆជាតិ ១ កក្កដា ឆ្នាំ២០១៤ ដែលប្រារព្ធឡើងនៅអាងទឹកក្តុល ភូមិក្រាំងកន្ទ្រោល ឃុំពាម ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង ។ កូនត្រីចម្រុះចំនួន ១ លានក្បាល កូនបង្កង ១ សែនក្បាល និងមេត្រីពូជមួយចំនួនដូចជាត្រីគល់រាំង ត្រីអណ្តែង ត្រីក្រាញ់ និងត្រីផ្ទក់ ។ល។ ត្រូវបានលែងដើម្បីធ្វើឱ្យអាងទឹកនេះសម្បូរទៅដោយត្រី និងបង្កងឡើងវិញសម្រាប់បម្រើសេចក្តីត្រូវការហូបចុករបស់ប្រជាពលរដ្ឋ ។

-ថ្ងៃទី ៣ កក្កដា សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញជាអធិបតីនៅក្នុងពិធីប្រកាសជាផ្លូវការដាក់ឱ្យអនុវត្តនីផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ និងអបអរសាទរខួបគម្រប់ ៥ ឆ្នាំ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ។ ក្នុងឱកាសនោះ សម្តេចបានមានប្រសាសន៍ថា ការការពារ និងលើកកម្ពស់សិទ្ធិជនពិការ ការដាក់បញ្ចូលពិការភាពទៅក្នុងការអភិវឌ្ឍគ្រប់លំដាប់ថ្នាក់ ឆ្ពោះទៅរកសង្គមមួយសម្រាប់ទាំងអស់គ្នា ដើម្បីធ្វើឱ្យសិទ្ធិក្លាយជាការពិត ។ សម្តេចក៏បានផ្តល់នូវការណែនាំជាច្រើនប្រយោជន៍ ដើម្បីឱ្យការអនុវត្តផែនការនេះទទួលបានជោគជ័យនោះ ។

-ថ្ងៃទី ១០-១១ និង ១២ កក្កដា ព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់**ព្រះបរមអដ្ឋិព្រះបរមរតនកោដ្ឋ** បានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។ នៅក្នុងព្រះរាជពិធីដង្ហែ **ព្រះបរមអដ្ឋិ** ព្រឹកថ្ងៃទី ១១ កក្កដា បានប្រារព្ធឡើងក្រោមព្រះរាជ អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចម៉ែ** សម្តេច **ព្រះនរោត្តម សីហមុនី** ព្រះរាជវង្សានុវង្ស និងថ្នាក់ដឹកនាំកំពូលៗ រួមមានសម្តេចតេជោ **ហ៊ុន សែន** សម្តេចចក្រី **ហេង សំរិន** ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រីជាច្រើនរូបផ្សេងទៀត ។

-ថ្ងៃទី ១០ កក្កដា រដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ហៅកាត់ថា JICA បានផ្តល់ហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទានចំនួន ១៥០ លានដុល្លារអាមេរិកសម្រាប់អនុវត្តនីគម្រោងចំនួន៤នៅកម្ពុជា ។ កិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន និងឥណទាននេះត្រូវបានចុះហត្ថលេខាដោយឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តម Hiroshi Izaki ប្រធាន JICA ប្រចាំកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ ។

-ថ្ងៃទី ១០ កក្កដា តាមការបញ្ជាក់ពីឯកឧត្តម Eric Sidgwick នាយកធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា ក្នុងឱកាសជួបជាមួយឯកឧត្តម **ជា សុផារ៉ា** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទនៅទីស្តីការក្រសួងបានឱ្យដឹងថាធនាគារអភិវឌ្ឍន៍អាស៊ីនិងបន្តផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការលើគម្រោងស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍ជនបទឆ្នាំ ២០១៤-២០១៨ ដូចជាការកសាងផ្លូវកៅស៊ូ ផ្លូវលំ ស្ពាន អណ្តូងទឹកស្អាត ប្រឡាយ និងស្រះទឹកសម្រាប់កសិកម្ម ។

-ថ្ងៃទី ១៤ កក្កដា សម្តេច **ព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ** ជាទីសក្ការៈ ព្រះអង្គបានសព្វព្រះរាជហឫទ័យប្រោសព្រះរាជទាននូវសារលិខិតសម្តែងនូវអំណរព្រះគុណផ្ញើជូនសម្តេចតេជោ **ហ៊ុន សែន** ចំពោះការចាត់ចែងរៀបចំព្រះរាជពិធីបុណ្យដង្ហែ និងតម្កល់**ព្រះបរមអដ្ឋិ** ( **ព្រះបរមរតនកោដ្ឋ**) ចាប់ពីថ្ងៃទី ១០ ដល់ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៤ នោះ ។

-ថ្ងៃទី ១៥ កក្កដា ឯកឧត្តម **បារ៉ាក់ អូបាម៉ា** ប្រធានាធិបតីសហរដ្ឋអាមេរិក បានផ្ញើសារលិខិតថ្លែងអំណរគុណជូនចំពោះសម្តេចតេជោ **ហ៊ុន សែន** ដែលបានផ្ញើសារលិខិតអបអរសាទរក្នុងឱកាសខួបលើកទី ២៣៤ នៃឯករាជ្យភាពរបស់សហរដ្ឋអាមេរិក ។

-ថ្ងៃទី ១៨ កក្កដា សម្តេចតេជោ **ហ៊ុន សែន** អញ្ជើញជាអធិបតីភាពក្នុងពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌននៃសាសនិកឥស្លាមកម្ពុជានៅមជ្ឈមណ្ឌលកោះពេជ្រ រាជធានីភ្នំពេញ សម្តេចបានមានប្រសាសន៍ថា នេះជាការចាប់ផ្តើមនៅឆ្នាំទី ១ ហើយយើងនឹងជួបគ្នាជារៀងរាល់ឆ្នាំសម្រាប់កម្មវិធីដ៏មានសារសំខាន់នេះ ។

-ថ្ងៃទី ២១ កក្កដា សម្តេចចក្រី **ហេង សំរិន** បានអនុញ្ញាតឱ្យឯកឧត្តម **ង៉ូ អាញ ហ្សុង** (Ngo Anh Dung) ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំនៅកម្ពុជាចូលជួបសម្តែងការគួរសម និងជម្រាបលា នៅវិមានរដ្ឋសភា ។ ក្នុងឱកាសនោះឯកឧត្តមបានថ្លែងពីគម្រោងនៃការបង្កើតឱ្យមាននូវសាលាមិត្តភាពរវាងកម្ពុជា និងវៀតណាមនាពេលខាងមុខ ដែលនឹងត្រូវចំណាយទឹកប្រាក់ប្រមាណជាង ២ លានដុល្លារអាមេរិក ។



*ព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សព្វព្រះរាជហឫទ័យព្រះបរមរាជានុញ្ញាត ថ្នាក់ដឹកនាំកំពូលនៃ**គណបក្សប្រជាជនកម្ពុជា** និង**គណបក្សសង្គ្រោះជាតិ** ចូលក្រាបបង្គំគាល់នៅក្នុងព្រះបរមរាជវាំង*

-ថ្ងៃទី ២២ កក្កដា បន្ទាប់ពីជំនួបចរចាថ្នាក់កំពូលរវាងគណបក្សប្រជាជនកម្ពុជានិងគណបក្សសង្គ្រោះជាតិនៅវិមានព្រឹទ្ធសភារួចមក សម្តេចតេជោ **ហ៊ុន សែន** បានប្រាប់អ្នកកាសែតថា ការចរចាទទួលបានជោគជ័យ ។ ចំណែកលោក សម រង្ស៊ី វិញនិយាយថា ការចរចាលើកនេះអាចបញ្ចប់ជម្លោះក្រោយការបោះឆ្នោតបានហើយ ។ កិច្ចប្រជុំកំពូលនេះបានសម្រេចកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយដ៏ទូលំទូលាយចំពោះបញ្ហាដែលបានកើតមានអស់រយៈពេលជិតមួយឆ្នាំ និងបាននាំមកនូវក្តីសប្បាយរីករាយសម្រាប់ប្រជាជនកម្ពុជានៅទូទាំងប្រទេស ។

-ថ្ងៃទី ២៣ កក្កដា នៅវិមានរដ្ឋាភិបាលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ **គាត ឈន់** អនុប្រធានទី ១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា និងឯកឧត្តម Joachim Baron Von Marcshall ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំកម្ពុជា តំណាងឱ្យរាជរដ្ឋាភិបាលអាល្លឺម៉ង់ បានចុះហត្ថលេខាផ្តល់ហិរញ្ញប្បទាននូវទឹកប្រាក់ ៦៤ លានដុល្លារអាមេរិកដល់ប្រទេសកម្ពុជា ដើម្បីគាំទ្រដល់គម្រោងជាអាទិភាពចំនួន ៣ រួមមានវិស័យសុខាភិបាល អភិវឌ្ឍន៍ជនបទ និងអភិបាលកិច្ច ។

-ថ្ងៃទី ២៤ ខែកក្កដា ថ្នាក់ដឹកនាំកំពូលនៃគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ បានចូលក្រាបបង្គំគាល់ព្រះករុណាព្រះបាទសម្តេច **ព្រះបរមនាថនរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីជំនួបចរចាទទួលបានជោគជ័យ ។

-ថ្ងៃទី ២៥ កក្កដា នៅវិមានព្រឹទ្ធសភា ក្នុងឱកាសជួបពិភាក្សាជាមួយឯកឧត្តម **សាយ ឈុំ** អនុប្រធាន ទី ១ ព្រឹទ្ធសភា ឯកឧត្តម Jao Chim Baron von Marschall ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធអាល្លឺម៉ង់ បានសម្តែងនូវការអបអរសាទរចំពោះកិច្ចពិភាក្សាបញ្ចប់បញ្ហានយោបាយនានារវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ ដែលបានកើតឡើងក្រោយការបោះឆ្នោតសកលកាលពីថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០១៣ កន្លងទៅនេះ ។

-ថ្ងៃទី ២៦ កក្កដា លោកជំទាវឧបនាយករដ្ឋមន្ត្រី **ម៉ែន សំអន** រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានចូលរួមក្នុងពិធីដាំកូនឈើនៅតំបន់ជាយជើងភ្នំគូលេន លើផ្ទៃដីជាង ៦ ហិកតា ដែលជាទីសំណាក់អាស្រម ស្ថិតនៅភូមិសំរោង ឃុំពពេល ស្រុកសូទ្រនិគម ខេត្តសៀមរាប ដើម្បីបង្កើនធនធានព្រៃឈើ សំដៅប្រែក្លាយតំបន់នោះប្រកបដោយគម្របពណ៌បៃតង និងជួយទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាកំសាន្ត ។

-ថ្ងៃទី ២៨ កក្កដា នៅវិមានរដ្ឋសភា សម្តេចចក្រី **ហេង សំរិន** បានអញ្ជើញជាអធិបតីបើកកិច្ចប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី ៥ ដើម្បីប្រកាសសុពលភាពនៃអាណត្តិឯកឧត្តម សម រង្ស៊ី ជាសមាជិកសភាអាណត្តិទី ៥ នៃរដ្ឋសភា ។ សម្តេចតេជោ **ហ៊ុន សែន** ដែលមានវត្តមាននៅក្នុងឱកាសនោះដែរបានមានប្រសាសន៍ថា ការផ្តល់សុពលភាពសភាដល់ឯកឧត្តម សម រង្ស៊ី ជាដំណើរការល្អ ។/

# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

**អាកាសចរណ៍ឆមាសទីមួយ :**

យោងទៅតាមស្ថិតិដែលទទួលបានពីក្រុមហ៊ុនព្រលានយន្តហោះកម្ពុជាបានឱ្យដឹងថា នៅក្នុងរយៈពេល ឆមាសទីមួយនៃឆ្នាំ ២០១៤ នេះ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ វិស័យដឹកជញ្ជូនតាមផ្លូវអាកាសគឺមានកំណើនប្រមាណជាង ១០% ខណៈដែលនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបមានកំណើន ១០% បើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣។

តួលេខបានបង្ហាញថា នៅក្នុងចន្លោះពីខែមករាដល់ខែមិថុនា អាកាសយានដ្ឋានអន្តរជាតិភ្នំពេញទទួលបានអ្នកដំណើរសរុបប្រមាណ ១,២៩ លាននាក់ បើធៀបនឹងរយៈពេលដូចគ្នានៅក្នុងឆ្នាំ ២០១៣ កន្លងទៅ គឺកើនឡើងប្រមាណ ១០,២៥%។ ដោយឡែកនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបវិញ មានចំនួនប្រមាណ ១,៥៣ លាននាក់ កើនឡើងប្រមាណ ១០% ។

ចំពោះចំនួនអ្នកដំណើរនៅអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុក៏មានកំណើនខ្ពស់ផងដែរ ដោយ នៅក្នុងរយៈពេលឆមាសទីមួយនេះបានទទួលអ្នកដំណើរប្រមាណ ១៧ ៧០០ នាក់ ក្នុងនោះ ៩៨% គឺជាអ្នកដំណើរតាមជើងហោះហើរក្នុងស្រុក ។

បច្ចុប្បន្នអាកាសយានដ្ឋានអន្តរជាតិដែលជាច្រកចេញ និងចូលដ៏សំខាន់នៃអ្នកដំណើរ និងអ្នកទេសចរបរទេសចូលមកកាន់ប្រទេសកម្ពុជា គឺអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាប។ ដោយឡែកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុរំពឹងថានឹងទទួលបានជើងហោះហើរភ្ជាប់ការធ្វើដំណើរពីចិន និងកូរ៉េខាងត្បូង នៅក្នុងវង្វង់ចុងឆ្នាំ ២០១៤ ។

សព្វថ្ងៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងខេត្តសៀមរាប បានភ្ជាប់កម្ពុជាទៅនឹងប្រទេសមួយចំនួននៅតំបន់អាស៊ានដូចជា ថៃ សិង្ហបុរី ម៉ាឡេស៊ី មីយ៉ាន់ម៉ា វៀតណាម ។ ក្រៅពីអាស៊ាន គឺមានដូចជា ចិន កូរ៉េខាងត្បូង បារាំង ជាដើម ។ គេរំពឹងថា នៅចុងឆ្នាំនេះនឹងមានជើងហោះហើរត្រង់ពីជប៉ុនមួយទៀត ។

**ការនាំអង្ករចេញឆមាសទីមួយ :**

ក្នុងឆមាសទីមួយឆ្នាំ ២០១៤ នេះ បរិមាណអង្ករកម្ពុជាមានចំនួន ១៧៧ ៩២៨ តោន ក្នុងនោះមានអង្ករចំនួន ៩ ប្រភេទត្រូវបាននាំចេញ។ អង្ករក្រអូបផ្កាម្លិះ ផ្ការំដួល ជាប្រភេទអង្ករដែលត្រូវបាននាំចេញច្រើនជាងគេ ដោយមានរហូតដល់ចំនួន ៦៦ ៣៤១ តោន។

គោលដៅនៃការនាំចេញអង្កររបស់កម្ពុជាក្នុងឆមាសទីមួយនេះដែរ មានចំនួន ៥៤ ប្រទេស ក្នុងនោះ ប្រទេសនៅអឺរ៉ុប គឺ ប៉ូឡូញ ជាប់លំដាប់ថ្នាក់លេខ ១ ដែលអង្ករកម្ពុជានាំចេញចំនួន ៣៣ ៦០៥ តោន។ លេខ ២ ប្រទេសបារាំង ចំនួន ៣៣ ៥១៧ តោន និងលេខ ៣ ប្រទេសហូឡង់ចំនួន ១៧ ៣៨១ តោន។ ចំណែកក្រុមហ៊ុនដែលនាំអង្ករចេញពីកម្ពុជាមានចំនួន ៦៤ ក្រុមហ៊ុន។ ក្នុងនោះមានក្រុមហ៊ុន Amru Rice បាននាំមុខគេ ដោយបាននាំអង្ករចេញចំនួន ២៥ ០៩៩ តោន។ លេខ ២ ក្រុមហ៊ុន Khmer Food មានចំនួន ២៣ ៧៧១ តោន និងលេខ ៣ ក្រុមហ៊ុន Golden Rice ចំនួន ១២ ៦២៩ តោន។

ជាការកត់សម្គាល់កាលពីឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលនយោបាយជំរុញការនាំចេញអង្ករដែលមានគុណភាពខ្ពស់ និងមធ្យមឱ្យបានយ៉ាងតិចមួយលានតោននៅឆ្នាំ ២០១៥។

របាយការណ៍បានបញ្ជាក់ថានៅឆ្នាំ២០០៩កម្ពុជាបាននាំអង្ករចេញចំនួន ១២ ៦១៣ តោន។ ឆ្នាំ ២០១០ ចំនួន ១០៥ ២៥៩ តោន។ ឆ្នាំ ២០១១ ចំនួន ២០១ ៨៩៩ តោន។ ឆ្នាំ ២០១២ ចំនួន ២០៥ ៧១៧ តោន និងឆ្នាំ ២០១៣ ចំនួន ៣៧៨ ៨៥៦ តោន។

**វិនិយោគរបស់ជប៉ុននៅកម្ពុជា និងទំនាក់ទំនងពាណិជ្ជកម្ម :**

ទំហំវិនិយោគទុនជប៉ុននៅប្រទេសកម្ពុជាបានកើនឡើងពីចំនួនប្រមាណ ៤០០ លានដុល្លារអាមេរិកនាឆ្នាំ២០១១ មកដល់ចំនួន ៥១៣ លានដុល្លារ នៅឆ្នាំ ២០១៣។ ដោយឡែក បើគិតពីឆ្នាំ ១៩៩៤ មកត្រឹមដំណាច់ខែឧសភា ឆ្នាំ ២០១៤ នេះ គម្រោងវិនិយោគជប៉ុននៅកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានចំនួន ៨៦ គម្រោង ដោយមានទឹកប្រាក់សរុបប្រមាណជិត ៦២០ លានដុល្លារ។

ការវិនិយោគផ្សារទំនើបអ៊ីអនម៉ល ដែលបានសម្ពោធកាលពីថ្ងៃទី ៣០ ខែមិថុនាកន្លងទៅនេះ គឺមានទឹកប្រាក់ប្រមាណ ២៥០ លានដុល្លារ។ នេះជាគម្រោងវិនិយោគធំជាងគេ។ ក្រៅពីគម្រោងផ្សារទំនើបអ៊ីអន ក៏មានគម្រោងវិនិយោគលើវិស័យឧស្សាហកម្មផ្សេងៗដូចជាផលិតម៉ូទ័រខ្នាតតូច គ្រឿងបង្គុំរថយន្ត និងគ្រឿងអេឡិចត្រូនិក រោងចក្រកាត់ដេរជាដើម។

ក្រៅពីទំហំវិនិយោគទាំងនេះ អង្គការពាណិជ្ជកម្មក្រៅប្រទេសជប៉ុនបានឱ្យដឹងថាទំហំពាណិជ្ជកម្មរវាងកម្ពុជានិងប្រទេសជប៉ុនក៏មានការកើនឡើងផងដែរ។

តួលេខ ៥ ខែនៃឆ្នាំ ២០១៤ គឺគិតចាប់ពីខែមករា ដល់ខែឧសភា កម្ពុជាបាននាំចេញទៅជប៉ុនមានតម្លៃប្រមាណ ២៨៨,៨ លានដុល្លារអាមេរិក គឺកើនឡើងប្រមាណ ៤០%។ ដោយឡែកការនាំចេញរបស់ជប៉ុនមកកាន់កម្ពុជាវិញនោះ គឺមានការកើនឡើងប្រមាណ ៥,៣% ដោយមានតម្លៃ ៩១,៩ លានដុល្លារ។

ទំនិញដែលកម្ពុជានាំចេញទៅជប៉ុនមានដូចជា ផលិតផលពីឧស្សាហកម្មកាត់ដេរ អង្ករ ជលផល ម្រេច ជាដើម ។ ចំណែកកម្ពុជានាំចូលមកពីជប៉ុនវិញគឺមានដូចជា គ្រឿងអេឡិចត្រូនិច គ្រឿងម៉ាស៊ីន គ្រឿងសម្អាងជាដើម ។ល ។

សកម្មភាពពាណិជ្ជកម្ម និងវិនិយោគរវាងកម្ពុជា និងជប៉ុន គឺមានការកើនឡើងនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

**ពាណិជ្ជកម្មកម្ពុជាឆមាសទីមួយ :**

ក្រសួងពាណិជ្ជកម្មបានបញ្ជាក់ថា ក្នុងរយៈពេលឆមាសទីមួយ ឆ្នាំ ២០១៤ នេះ ទំហំពាណិជ្ជកម្មកម្ពុជា និងប្រទេសដៃគូនានា មានទំហំប្រមាណ ៨ ៩៥០ លានដុល្លារអាមេរិក គឺមានការកើនឡើងប្រមាណ ១៧% បើធៀបនឹងទឹកប្រាក់នៃទំហំពាណិជ្ជកម្មសរុបកាលពីឆមាសទី ១ ឆ្នាំ ២០១៣ ដែលមានតម្លៃត្រឹមតែ ៧ ៦១០ លានដុល្លារ ។

ឆមាសទី ១ នេះការនាំចេញសរុបរបស់កម្ពុជាទៅកាន់ទីផ្សារពិភពលោក គឺមានតម្លៃប្រមាណ ៣ ៧៧០ លានដុល្លារ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ គឺកើនប្រមាណ ២០% ។ ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ ការនាំចេញរបស់កម្ពុជាមានតម្លៃ ៣ ១៤០ លានដុល្លារ ។ ដោយឡែកការនាំចូលវិញនោះ នៅក្នុងរយៈពេលដដែលនេះ គឺមានទំហំតម្លៃប្រមាណ ៥ ១៨០ លានដុល្លារ គឺកើនឡើងប្រមាណ ១៦% ។ ឆ្នាំ ២០១៣ រយៈពេលដូចគ្នាមានចំនួន ៤ ៤៧០ លានដុល្លារ ។

រហូតមកដល់ពេលនេះ ផលិតផលសំខាន់ៗដែលកម្ពុជាបានធ្វើការនាំចេញភាគច្រើនជាផលិតផលសម្លៀកបំពាក់ និងស្បែកជើង ។ ផលិតផលកសិកម្ម មានដូចជា កៅស៊ូ អង្ករ ដំឡូងមី ពោត ម្រេចជាដើម ។ ចំណែកទំនិញនាំចូលមានដូចជា វត្ថុធាតុដើមសម្រាប់វិស័យឧស្សាហកម្មកាត់ដេរ គ្រឿងសំណង់ យានជំនិះ ប្រេងឥន្ធនៈ ម្ហូបអាហារ ភេសជ្ជៈ ឱសថ និងបរិក្ខាពេទ្យ គ្រឿងសម្អាង និងសារធាតុគីមីជាដើម ។

សព្វថ្ងៃនេះដៃគូនាំចេញរបស់កម្ពុជាគឺមាន អាមេរិក សហគមន៍អឺរ៉ុប អាស៊ាន កាណាដា ចិន ជប៉ុន ជាដើម ហើយដៃគូនាំចូលវិញគឺជាប្រទេសជិតខាងមាន ថៃ វៀតណាម ចិន ។ល ។

**ចំណូលពន្ធដារឆមាសទី ១ ឆ្នាំ ២០១៤**

អគ្គនាយកដ្ឋានពន្ធដារបានអោយដឹងថា នៅក្នុងឆមាសទី ១ នៃ ឆ្នាំ ២០១៤ ពន្ធដាររកបានចំណូលពន្ធប្រមាណ ២ ១២៩,៧ ពាន់លានរៀល ឬជាង ៥៣២ លានដុល្លារអាមេរិក ។ ចំនួននេះស្មើនឹង ៥៣,៣៦% នៃផែនការឆ្នាំ ២០១៤ ហើយ ។ ចំណូលប្រចាំឆមាសទី១នេះដែរ បើប្រៀបធៀបនឹងចំណូលឆមាសទី ១ ឆ្នាំ ២០១៣ គឺកើនឡើងប្រមាណ ១៣,៥% ក្នុងនោះរួមមានចំណូលថវិការដ្ឋចំនួន ៥៦,២% និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ៣៧,៣% ។ ដោយឡែកគ្រាន់តែប្រាក់ចំណូលនៅក្នុងខែមិថុនាតែមួយពន្ធដារប្រមូលបានចំនួន ៣១៤,៣៥ ពាន់លានរៀល ឬប្រមាណ ៧៨,៦ លានដុល្លារអាមេរិក ។



*រោងចក្រកាត់ដេរសម្លៀកបំពាក់មួយកន្លែងក្នុងរាជធានីភ្នំពេញ*

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលឆមាសទី ១ ឆ្នាំ ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗ ដូចជា ពន្ធលើប្រាក់បៀវត្សរ៍កើនឡើងប្រមាណ ២៣,៥% ពន្ធលើប្រាក់ចំណេញ កើនឡើង ២១,២% អាករលើតម្លៃបន្ថែមកើនឡើង ៩,១% និងអាករពិសេសកើនឡើង៥,៣% ។ប៉ុន្តែគួរកត់សម្គាល់ថាចំណូលពន្ធលើប្រេងឥន្ធនៈមានការថយចុះ ។

បើពិនិត្យតាមវិស័យវិញក្នុងរយៈពេលដូចគ្នាឃើញថាចំណូលមានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះ ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២០,២% ។ ផ្នែកស្ថាបត្យកម្ម និងសំណង់កើនឡើង ៦៧,១% ។ ផ្នែកអាជីវកម្មអចនទ្រព្យកើន ១២២,៧% ។ ផលិតផលភេសជ្ជៈកើនឡើង ២១% ។ ផ្នែកផលិតសម្លៀកបំពាក់កើនឡើង ៥៦% ។ ផ្នែកសណ្ឋាគារ ផ្ទះសំណាក់កើនឡើង ៤១% ។ ផ្នែកផលិតថ្នាំជក់កើនឡើង ១៦,៦% ។ លក់ភេសជ្ជៈកើនឡើង ៥១,២% ។ ផលិតម្ហូបអាហារកើន ៩៣,៤% ។ ផ្នែកលក់សម្ភារៈការិយាល័យ កើនឡើង ៤៥,៣% ។ ផ្នែកលក់គ្រឿងយន្តកើន ៥៧,៨% ។

**ការចុះបញ្ជីក្រុមហ៊ុនរយៈពេល៥ខែ**

ក្រសួងពាណិជ្ជកម្មបានឱ្យដឹងថារយៈពេល៥ខែគិតចាប់ពីខែមករាដល់ខែឧសភា ឆ្នាំ ២០១៤ នេះ ក្រុមហ៊ុនដែលមកចុះបញ្ជីមានចំនួន ១ ៦៧៦ ក្រុមហ៊ុន គឺមានការកើនឡើង៥៤,៣២% ។ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ គឺមានចំនួន ១ ០៨៦ ក្រុមហ៊ុន ។

ទិន្នន័យបង្ហាញទៀតថា ពីខែមករារហូតដល់ឧសភា ក្រុមហ៊ុនបរទេសបានចុះបញ្ជីចំនួន ៧៤៩ ក្រុមហ៊ុន គឺកើនឡើង ៤៥,៧១% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនដែលកាលនោះមានចំនួន ៥១៤ ក្រុមហ៊ុន ។ ចំណែកឯក្រុមហ៊ុនខ្មែរគឺមានចំនួន ៩២៧ ក្រុមហ៊ុន កើនឡើង ៦២% ។ ឆ្នាំ ២០១៣ ក្នុងរយៈពេលដូចគ្នាមានចំនួន ៥៧២ ក្រុមហ៊ុន ។/

# កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច ការប្រកួតប្រជែង និងការអភិវឌ្ឍ



*សិក្ខាសាលាផ្សព្វផ្សាយអំពីប្រព័ន្ធពន្ធដារកម្ពុជា ក្រោមអធិបតីភាពឯកឧត្តម **គង់ វិបុល***

ក្នុងគោលបំណងខិតខំសម្រេចកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពក្នុងអត្រា ៧% ក្នុងមួយឆ្នាំ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៥ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បាន និងកំពុងជំរុញការអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅលើវិស័យជាច្រើន ក្នុងនោះកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានតួនាទីដ៏សំខាន់ក្នុងការរួមចំណែកដល់ដំណើរការជំរុញកំណើនសេដ្ឋកិច្ច ការប្រកួតប្រជែង និងការអភិវឌ្ឍរបស់កម្ពុជា ។

កាលពីពេលថ្មីៗនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ កិច្ចប្រជុំនេះបានពិនិត្យ និងពិភាក្សាលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី ១ ឆ្នាំ ២០១៤ និងពិនិត្យពិភាក្សាលើការរៀបចំផែនការសកម្មភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ សម្រាប់ឆ្នាំ ២០១៤-២០១៥ ។

តាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានឱ្យដឹងថា សកម្មភាពនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានអនុវត្តនៅក្នុងត្រីមាសទី១ឆ្នាំ២០១៤បានបង្ហាញលទ្ធផលប្រសើរជាច្រើនលើផ្នែកភាពជឿទុកចិត្តបាននៃថវិកា ការកែលម្អគណនេយ្យភាព ហិរញ្ញវត្ថុ និងការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ។

របាយការណ៍បានបង្ហាញថា លទ្ធផលចំណូលក្នុងស្រុកសរុបជាបណ្តើរៗកាន់តែខិតទៅរកគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ ។បំណុលសាច់ប្រាក់កកស្ទះក៏ពុំមានរីឯចំណាយលើបៀវត្សរ៍ក៏សម្រេចបានទាន់ពេលវេលា ។ ជាមួយគ្នានេះដែរ តាមរយៈការអនុវត្តផែនការប្រតិបត្តិនៃផែនការសកម្មភាពរយៈពេលខ្លី ៦០ ថ្ងៃ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាធ្វើឱ្យលទ្ធផលនៃការប្រមូលពន្ធគយកាន់តែប្រសើរជាងមុន ។ ការត្រៀមលក្ខណៈសម្រាប់ការរៀបចំ និងដាក់ឱ្យអនុវត្តគម្រោងគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាមានលក្ខណៈល្អប្រសើរ ។ យុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកាដែលជាការងារដ៏មានសារៈសំខាន់នៃកម្មវិធីកែទម្រង់ក៏ត្រូវបានពង្រឹងតាមរយៈការដាក់ឱ្យអនុវត្តជាជំហានៗនូវថវិកាតាមកម្មវិធី និងអង្គភាពថវិកា ។របាយការណ៍បានឱ្យដឹងទៀតថា ការរៀបចំផែនការសកម្មភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ២ សម្រាប់ឆ្នាំ ២០១៤-២០១៥ របស់គ្រប់ក្រសួង ស្ថាប័នទាំងអស់ បានចាប់ផ្តើមអនុវត្តពីខែមិថុនា ឆ្នាំ ២០១៤ នេះតទៅ ។ ហើយឆ្នាំ ២០១៤ គឺជាឆ្នាំត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ពិសេសការដាក់ឱ្យអនុវត្តពេញលេញថវិកាកម្មវិធី និងការដាក់ឱ្យអនុវត្តអង្គភាពថវិកា ។

របាយការណ៍បានឱ្យដឹងទៀតថា ក្រសួងក៏បានជំរុញឱ្យមានយន្តការថ្មីៗបន្ថែមទៀត ដើម្បីធ្វើការតាមដានដល់ក្រសួងស្ថាប័នដែលពុំទាន់បានបញ្ចប់ផែនការសកម្មភាពរបស់ខ្លួន ដើម្បីខិតខំប្រឹងប្រែងផ្ញើមកអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ឱ្យបានទាន់ពេលវេលា ព្រោះឆ្នាំ ២០១៥ នឹងក្លាយជាឆ្នាំអន្តរកាលនៃការផ្លាស់ប្តូរពីការបញ្ចប់ដំណាក់កាលទី ២ ទៅការរៀបចំផែនការសកម្មភាពដំណាក់កាលទី ៣( ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ) ដែលនឹងត្រូវចាប់ផ្តើមពេញលេញនៅឆ្នាំ ២០១៦ ។ ចំពោះលទ្ធផលនៃការអនុវត្តកម្មវិធីកែទម្រង់ការប្រមូលពន្ធនៅក្នុងខែឧសភាឆ្នាំ២០១៤កន្លងមកគឺអគ្គនាយកដ្ឋានពន្ធដារប្រមូល និងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៣៦៤ ៧៤១ លានរៀល ស្មើនឹង ៩១,២ លានដុល្លារអាមេរិក បើប្រៀប ធៀបនឹងចំណូលពន្ធក្នុងខែឧសភា ឆ្នាំ ២០១៣ មានការកើនឡើង ស្មើនឹង ២៥,៤% ក្នុងនោះថវិការដ្ឋកើនឡើង ស្មើនឹង ៣៦,៧% ។

នៅក្នុងសេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែឧសភា ឆ្នាំ ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារក្នុងរាជធានីភ្នំពេញកាលពីថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០១៤ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានឱ្យដឹងថា ក្នុងរយៈពេល ៥ ខែ ក្នុងឆ្នាំ ២០១៤ អគ្គនាយកដ្ឋានពន្ធដារ បានប្រមូល និងបង់ពន្ធចូលថវិកាជាតិ បានចំនួនស្មើនឹង ៤៥,៧៧% នៃគោលដៅកំណត់ក្នុងច្បាប់ ក្នុងនោះថវិការដ្ឋសម្រេចបានចំនួនស្មើនឹង ៤៨,៤% និងថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបានចំនួនស្មើនឹង ២៩,១% ។ បើប្រៀបធៀបរយៈពេល ៥ ខែ ឆ្នាំ ២០១៣ ឃើញថា ការប្រមូលពន្ធដារបង់ចូលថវិកាជាតិរយៈពេល ៥ ខែ ឆ្នាំ ២០១៤ នេះ មានការកើនឡើង ១២,៥% ក្នុងនោះ ថវិការដ្ឋកើនឡើង ១៤,៦% ។



*កិច្ចប្រជុំរបស់អគ្គនាយកដ្ឋានពន្ធដារស្តីពីវិធានការប្រមូលពន្ធឱ្យបានគ្រប់ជ្រុងជ្រោយដើម្បីប្រមូលថវិកាចូលរដ្ឋ*

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធក្នុងនោះ ប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជាពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ១៩,២% ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ១៩.៨% អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ៥,៩% និងអាករពិសេសកើនឡើងប្រមាណ ៤,៥% ។

ការពិនិត្យតាមវិស័យឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២០% ផ្នែកស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៦១,៧% ផលិតភេសជ្ជៈកើនឡើងប្រមាណ ១៥,៨% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ២៦៣% ផលិតសម្លៀកបំពាក់ កើនឡើងប្រមាណ ៥៧,៨% ផ្នែកសណ្ឋាគារ និងផ្ទះសំណាក់ កើនឡើងប្រមាណ ៤១,៩% នីហរ័ណ អាហរ័ណ កើនឡើងប្រមាណ ១១,៦% ទូរគមនាគមន៍កើនឡើងប្រមាណ ៣,២% ដឹកជញ្ជូន និងទេសចរណ៍ កើនឡើងប្រមាណ ១៨,៨% លក់ភេសជ្ជៈ កើនឡើងប្រមាណ ៤៩,៤% ផលិតថ្នាំជក់ កើនឡើងប្រមាណ ១៩,៩% លក់សម្ភារៈការិយាល័យកើនឡើងប្រមាណ ៤៤,៩% ផលិតម្ហូបអាហារ កើនឡើងប្រមាណ ៩៣,១% អាកាសយានដ្ឋាន និងកំពង់ផែ កើនឡើងប្រមាណ ១២,៣% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ៤៥,៨% និងលក់គ្រឿងសំណង់កើនឡើងប្រមាណ ៧១,៥% ។

ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារដែលបានខិតខំប្រឹងប្រែងប្រមូលចំណូលពន្ធមានការកើនឡើងគួរជាទីពេញចិត្ត និងបានណែនាំដល់ប្រធានពន្ធដារគ្រប់លំដាប់ថ្នាក់ និងមន្ត្រីពន្ធដារទាំងអស់ឱ្យខិតខំពង្រឹងការអនុវត្តច្បាប់វិន័យ ការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឱ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាដល់អ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ដោយគោរពច្បាប់ និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឱ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធ ដើម្បីឱ្យការប្រមូលពន្ធកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀតឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៤។

ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានថ្លែងថា ចក្ខុវិស័យនៃយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនេះគឺផ្តោតលើការកៀរគរចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធឱ្យអស់សក្តានុពលនាពេលបច្ចុប្បន្ន ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងសម្រេចបាននូវបំណងប្រាថ្នា ក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០។ ឯកឧត្តមបន្តថា យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមនេះ បានរៀបចំឡើងក្នុងគោលបំណង ១-ពង្រឹងវចនាសម្ព័ន្ធប្រព័ន្ធពន្ធ និងមិនមែនសារពើពន្ធ លើកកម្ពស់វប្បធម៌នៃការបង់ពន្ធ និងការគោរពច្បាប់។ ២-ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ ដើម្បីរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ និងសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ដែលស្របនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ។ ៣-ពង្រីកលំហូរសារពើពន្ធ ដើម្បីពង្រឹងស្ថិរភាពសារពើពន្ធ ការគ្រប់គ្រងបំណុលប្រកប ដោយនិរន្តរភាព និងកាត់បន្ថយការពឹងផ្អែកលើហិរញ្ញប្បទានក្រៅប្រទេស និង ៤-បង្កើនទុនបម្រុងសារពើពន្ធសម្រាប់តម្រូវការបន្ទាន់របស់រាជរដ្ឋាភិបាល។ យុទ្ធសាស្ត្រនេះក៏ផ្តោតសំខាន់លើសសរស្តម្ភបីរួមមាន : ការពង្រឹងរដ្ឋបាល ការធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយ និងការពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃផងដែរ ។/



*សិក្ខាសាលាស្តីពីការផ្សព្វផ្សាយបទប្បញ្ញត្តិសារពើពន្ធ និងលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធក្នុងរបបម៉ៅការ*



*អតិថិជនចូលបង់ពន្ធលើមធ្យោបាយយានយន្តនៅធនាគារ*

# កម្ពុជានឹងសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នាឆ្នាំ ២០១៥ ក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋនៅទីជនបទឱ្យបាន ៥០%

*ក្រសួងអភិវឌ្ឍន៍ជនបទជាស្ថាប័នមួយរបស់រាជរដ្ឋាភិបាលដែលធ្វើការផ្ទាល់ជាមួយប្រជាជន ឆ្លើយតបតាមសំណូមពររបស់ប្រជាជន និងមានតួនាទីជាគន្លឹះក្នុងការធ្វើឱ្យមានការប្រែប្រួលរីកចម្រើននៅតាមជនបទ រួមចំណែកលើកកម្ពស់ជីវភាពរបស់ប្រជាជន និងជួយពង្រឹងពង្រីកកំលាំងសេដ្ឋកិច្ចមូលដ្ឋាន ។*

*តាមរបាយការណ៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងឆ្នាំ ២០១៣ កន្លងមកនេះបានឱ្យដឹងថា ក្រសួងបានចំណាយថវិកាជាង ១៧៧ ពាន់លានរៀល ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ ក្នុងនោះមានគម្រោងមួយចំនួនដូចជា កម្មវិធីទឹកស្អាត និងអនាម័យ ផ្គត់ផ្គង់ទឹក កែលម្អផ្លូវ ... ។*

*មានកម្មវិធីជាច្រើន ដូចជា កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ កម្មវិធីស្បៀងអាហារពិភពលោក គម្រោងស្តារឡើងវិញជាបន្ទាន់នូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតដោយខ្យល់ព្យុះកេតសាណា គម្រោងឥណទានខ្នាតតូច គម្រោងស្តារឡើងវិញហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងគម្រោងអភិវឌ្ឍន៍ជនបទដីទំនាបបឹងទន្លេសាប ។*

គម្រោងទាំងអស់នេះ ក្រសួងបានសហការក្នុងការអនុវត្តជាមួយបណ្តាអង្គការដៃគូក្រៅរដ្ឋាភិបាលមួយចំនួនមាន UNICEF ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិអភិវឌ្ឍន៍ណ័រឌីក (NDF) ធនាគាររបស់សាធារណរដ្ឋកូរ៉េ (KEXIM BANK) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AUSAID) ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ (KFW) និងវិទ្យាស្ថានសេដ្ឋកិច្ចជនបទកូរ៉េ (KREI) ។

របាយការណ៍ក្រសួងអភិវឌ្ឍន៍ជនបទបានបញ្ជាក់ថា កាលពីឆ្នាំ ២០១៣ ក្រសួងបានជំរុញការងារអភិវឌ្ឍសហគមន៍ ដោយបានជីកស្រះតាមគ្រួសារ ផ្តល់ពូជបន្លែចម្រុះ ផ្តល់ពូជត្រី មេគោ កូនជ្រូក ពូជមាន់ និងកូនឈើហូបផ្លែ ដើម្បីបង្កើនសេដ្ឋកិច្ចគ្រួសារ កែលម្អជីវភាពរស់នៅ ។ ទន្ទឹមនោះ មន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទបានបណ្តុះបណ្តាលគ្រូបង្គោលអំពីសញ្ញាណសន្តិសុខស្បៀង ដើម្បីជួយណែនាំប្រជាជនអំពីរបៀបធ្វើជីកំប៉ុសសម្រាប់ដាំដំណាំក្នុងគ្រួសារ ។

ក្រសួងអភិវឌ្ឍន៍ជនបទបានឱ្យដឹងថា នៅក្នុងកម្មវិធីឥណទានសហប្រតិបត្តិការជាមួយដៃគូ បណ្តាដៃគូបានផ្តល់ឥណទាន សរុបចំនួន ៦ ១៣១ ២៤៥ ២០០ រៀល ស្មើនឹង ១ ៥៣២ ៨១១,៣០ ដុល្លារ ដែលមានគ្រួសារខ្ចីចំនួន ៨ ៧២៣ គ្រួសារ នៅភូមិគោលដៅចំនួន ២៨០ ឃុំចំនួន ៩៦ និងស្រុកចំនួន ២៩ នៅក្នុងខេត្តកំពង់ចាម ពោធិសាត់ កំពត សៀមរាប កោះកុង បាត់ដំបង តាកែវ ស្វាយរៀង និងខេត្តបន្ទាយមានជ័យ ។

ដោយឡែកការអនុវត្តកម្មវិធីផ្គត់ផ្គង់ទឹកជនបទ ក្នុងឆ្នាំ ២០១៣ បានធ្វើឱ្យប្រជាពលរដ្ឋ ៤៥ ម៉ឺននាក់ បន្ថែមទៀតទទួលបានទឹកស្អាតប្រើប្រាស់ប្រចាំថ្ងៃ ដែលបានធ្វើឱ្យពួកគាត់មានសុខុមាលភាពប្រសើរឡើង ពិសេសកាត់បន្ថយជំងឺរាករូស ចំណេញពេលវេលារកចំណូលផ្គត់ផ្គង់គ្រួសារ ។

ក្នុងគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនេះ មានការចូលរួមពី



*ផ្លូវក្រាលគ្រួសក្រហមនៅក្នុងឃុំក្បឿងរាយ ស្រុកកញ្ជៀច ខេត្តព្រៃវែង*



*ស្រះទឹកស្អាតមាននៅទីអារាមនានា*



*ស្រះទឹកត្រូវបានជីកសម្រាប់ជាតម្រូវការទឹកស្អាតជូនប្រជាជនក្នុងសហគមន៍*

ដៃគូអភិវឌ្ឍន៍សំខាន់ៗ ដូចជា ធនាគារ អភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក អង្គការសុខភាពពិភពលោក UNICEF WFP និងមានកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការផ្សេងទៀតផងដែរ ។

កាលពីឆ្នាំ ២០១៣ ធនាគារអភិវឌ្ឍន៍អាស៊ីបានផ្តល់ថវិកាចំនួន ៦៧៨ ៦០៨ ដុល្លារ សម្រាប់សាងសង់អណ្តូងគ្រប់ប្រភេទបាន ៣០៥ ប្រភពទឹកស្អាតផ្សេងទៀតចំនួន ៩៥៦៥ កន្លែងនិងបង្គន់អនាម័យចំនួន ៧ ៤៩៧ ។ ក្រៅពីនេះ បានជួសជុលអណ្តូងគ្រប់ប្រភេទបាន ៥៩ និងស្រះសហគមន៍ចំនួន ១០ ។ ដោយឡែកអណ្តូងទឹកគ្រប់ប្រភេទចំនួន ១៨០ អាងត្រងទឹកភ្លៀង ៤១ និងធុងចម្រោះជីវសាស្ត្រ ១០០ ធុងត្រូវបានកសាងដោយថវិកាជាតិផងដែរ ។

ប៉ុន្តែទោះជាយ៉ាងណាក្តី ប្រជាពលរដ្ឋប្រមាណជា ២ លាននាក់កំពុងតែបន្តរស់នៅក្នុងតំបន់ដែលមានទឹកផ្ទុកសារធាតុអាសេនិកខ្ពស់នៅឡើយ ។ លោក ម៉ៅ សារ៉ាយ ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទបានឱ្យដឹងថា មានភូមិចំនួន ១ ៦០៧ ស្ថិតក្នុងខេត្តចំនួន ៧ នៅទូទាំងប្រទេសត្រូវបានរកឃើញថា ទឹកមានផ្ទុកសារធាតុអាសេនិកខ្ពស់ ហើយនៅក្នុងភូមិទាំងនោះមានពលរដ្ឋចំនួន ២ លាន ២ សែននាក់កំពុងរស់នៅ ។

តាមការស្រាវជ្រាវរកឃើញថា មានពលរដ្ឋពី ១ សែន ទៅ ២ សែននាក់ ដែលកំពុងប្រើប្រាស់ទឹកដែលមានជាតិអាសេនិក ហើយទឹកដែលមានអាសេនិកច្រើនជាងគេគឺខេត្តកណ្តាល ។ ដើម្បីដោះស្រាយបញ្ហាអាសេនិកនេះ ក្រសួងអភិវឌ្ឍន៍ជនបទបានសហការជាមួយនឹងអង្គការ UNICEF និងអង្គការផ្សេងៗទៀត ដោយបង្កើតប្រព័ន្ធចែកចាយទឹកខ្នាតតូច និងកសាងអាងត្រងទឹកភ្លៀងសម្រាប់ពលរដ្ឋប្រើប្រាស់បានខ្លះផងដែរ ។ ដោយឡែកនៅខេត្ត ៦ ផ្សេងទៀតដែលត្រូវបានអះអាងថា ទឹកមានផ្ទុកជាតិអាសេនិកខ្ពស់នោះ នៅមិនទាន់បានបង្ហាញជាផ្លូវការនោះទេ ។ ទោះយ៉ាងណាលោក ម៉ៅ សារ៉ាយ ប្រធាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទបានបញ្ជាក់ថា សារធាតុអាសេនិក គឺត្រូវបានរកឃើញនៅក្នុងខេត្តដែលនៅតាមដងទន្លេមេគង្គ ដូចជាកំពង់ចាម កណ្តាល និងក្រចេះជាដើម ។ លោក ជ្រាយ ប៉ុម ប្រធាននាយកដ្ឋានថែទាំសុខភាពជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ លើកឡើងថា "សារធាតុនេះវាប្រែប្រួលពីខេត្តមួយទៅមួយ ហើយយើងបានធ្វើផែនទីក្នុងខេត្តនីមួយៗស្តីពីកម្រិតជាតិអាសេនិកនេះហើយ" ។ លោកបន្តថា ក្រសួងបានធ្វើតេស្តទឹកអណ្តូងមុនដាក់ឱ្យពលរដ្ឋប្រើប្រាស់ ។ បើលទ្ធផលបង្ហាញថា សារធាតុអាសេនិកមានក្រោម ៥០ ផផប នោះនឹងដំឡើងអណ្តូងស្នប់ឱ្យបរិភោគនិងប្រើប្រាស់ទឹកបាន ។ តែបើមានជាតិអាសេនិកលើសពី ៥០ ផផប វិញ ក្រសួងនឹងលាញ់ថ្នាំពណ៌ក្រហមលើអណ្តូងនោះសម្គាល់ថា ទឹកអណ្តូងនោះមិនអាចបរិភោគបានទេ តែ



ប្រជាជននៅសង្កាត់សំរោង ខេត្តឧត្តរមានជ័យប្រើប្រាស់ទឹកអណ្តូងស្នប់



សកម្មភាពត្បាញរពាក់របស់ប្រជាកសិករ ក្រោយពីការបង្កបង្កើនផល



ប្រជាជនក្នុងសហគមន៍ខិតខំពង្រីកដំណាំអនុផលលើកស្ទួយកម្រិតជីវភាព



ជាមួយនឹងរបរកសិកម្ម ប្រជាជនកម្ពុជានៅបានចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

អាចប្រើប្រាស់បាន ។ លើសពីនោះ ក្រសួងក៏មានបើកវគ្គបណ្ដុះបណ្ដាល និងអប់រំពលរដ្ឋពីគ្រោះថ្នាក់នៃសារធាតុអាសេនិកនេះផងដែរ ។

ក្នុងសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ ២០១៣ នៅសាល សន្និសីទចតុមុខ ក្នុងរាជធានីភ្នំពេញ លោក ជ្រាយ ប៉ុម បានថ្លែងថា ប្រទេសកម្ពុជាអាចនឹងសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅឆ្នាំ ២០១៥ ក្នុងការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋនៅទីជនបទឱ្យបាន ៥០% តាមការគ្រោងទុក ។ លោកបានបញ្ជាក់ថា ទិន្នន័យពីការធ្វើជំរឿនប្រជាជនឆ្នាំ ២០១៣ បានបង្ហាញថា អត្រាភាគរយនៃពលរដ្ឋកម្ពុជានៅជនបទដែលបានកែលម្អប្រភពទឹកប្រើប្រាស់បានកើនដល់ ៤៩% ។ ដូចនេះយើងអាចសម្រេចបានគោលដៅសហស្សវត្សរ៍នេះ ។

ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** បានមានប្រសាសន៍ក្នុងឱកាសសន្និបាតបូកសរុបការងារប្រចាំឆ្នាំ ២០១៣ និងទិសដៅការងារអនុវត្តបន្តក្នុងឆ្នាំ ២០១៤ របស់ក្រសួងអភិវឌ្ឍន៍ជនបទថា រាជរដ្ឋាភិបាលនីតិកាលទី ៥ ដែលបានប្រសូតចេញពីឆន្ទៈប្រជាពលរដ្ឋកាលពីថ្ងៃទី ២៨ កក្កដា ឆ្នាំ ២០១៣ កន្លងមកនេះ បានកើតឡើងក្នុងដំណាក់កាលមួយដែលសេដ្ឋកិច្ចប្រទេសបានបង្ហាញនូវភាពរឹងមាំរបស់ខ្លួនឆ្ពោះទៅសម្រេចគោលដៅនៃកំណើនសេដ្ឋកិច្ច ៧% ក្នុងការអភិវឌ្ឍប្រទេស ។ ទោះបីជាកំណើននោះនៅមានភាពផុយស្រួយ និងមានហានិភ័យខ្ពស់ ដោយសារភាពពុំប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោក និងគ្រោះមហន្តរាយដែលបានកើតឡើង ផ្ទួនៗគ្នាកាលពីឆ្នាំមុនៗយ៉ាងណាក្ដី ក៏រាជរដ្ឋាភិបាលបានជម្នះនូវផលវិបាកដែលកើតចេញពីវិបត្តិសេដ្ឋកិច្ចពិភពលោកទាំងឡាយនោះ សម្រេចបាននូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ១ ទី ២ និងធានានូវចិរភាពស្ថិរភាពនយោបាយ សន្តិសុខ សណ្ដាប់ធ្នាប់សង្គម ដែលបានលើកស្ទួយការពង្រឹងនីតិរដ្ឋការពារសិទ្ធិរបស់ប្រជាពលរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

សូមបញ្ជាក់ថា ទោះបីជាវិបត្តិសេដ្ឋកិច្ចហិរញ្ញវត្ថុសកលលោកជះឥទ្ធិពលក្នុងឆ្នាំ ២០០៩ មកលើកម្ពុជាយ៉ាងណាក្ដី ក៏កំណើនសេដ្ឋកិច្ចកម្ពុជានៅតែមានលក្ខណៈវិជ្ជមាន ក្នុងនោះនៅឆ្នាំ ២០១០ សេដ្ឋកិច្ចកម្ពុជាបានងើប ឡើងដល់ ៦% ហើយឆ្នាំ ២០១១ និង ២០១២ មានកំណើនក្នុងរង្វង់ ៧% និងបានធ្វើឱ្យផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់ៗកើនឡើងពី ៧៦០ ដុល្លារអាមេរិកក្នុងឆ្នាំ ២០០៨ ដល់ ជិត ១០០០ ដុល្លារក្នុងឆ្នាំ ២០១២ ហើយកើនឡើងដល់ជាង ១០០០ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៣ កន្លងទៅនេះ ។

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥ បាននិងកំពុងអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅរបស់ខ្លួន ដើម្បីប្រែក្លាយប្រទេសកម្ពុជាពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបឱ្យបានក្នុងរយៈពេលខ្លីខាងមុខ និងបន្តប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ ២០៣០ ហើយនឹងបន្តប្រែក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ ២០៥០ ។ នេះជាមហិច្ឆតានៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីប្រជាជាតិកម្ពុជាទាំងមូល ។



*ការចិញ្ចឹមមាន់-ទា ជាលក្ខណៈគ្រួសាររបស់ប្រជាកសិករក្នុងសហគមន៍*

ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆតានេះ ប្រការមួយដ៏សំខាន់គឺត្រូវផ្ដែកមួយផ្នែកធំទៅលើការលើកកម្ពស់សមត្ថភាពរបស់ប្រជាជនយើងតាមរយៈការអភិវឌ្ឍន៍ចំណេះដឹងនិងជំនាញវិជ្ជាជីវៈប្រកបដោយគុណភាពខ្ពស់ និងរត់ទាន់សភាពការណ៍វិវត្តន៍របស់ទីផ្សារតំបន់ និងពិភពលោកជាប់ជាប្រចាំ ក្នុងនោះ វិស័យអភិវឌ្ឍន៍ជនបទ ពិតជាមានតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ច ការប្រកួតប្រជែង និងការអភិវឌ្ឍរបស់កម្ពុជា ។/



# ប្រយោជន៍ដ៏ធំធេងនៃការដាក់បញ្ចូល បេតិកភណ្ឌវប្បធម៌ជាតិ ជាបេតិកភណ្ឌពិភពលោក





*តំបន់ប្រាសាទបុរាណនានាក្នុងខេត្តសៀមរាប និងប្រាសាទព្រះវិហារ ត្រូវបានដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក*

ជាមោទនភាព និងកិត្តិយសដ៏ឧត្តុង្គឧត្តម ដែលព្រះរាជាណាចក្រកម្ពុជាយើងបានទទួលកន្លងមកក្នុងវិស័យវប្បធម៌ នោះគឺការដាក់បញ្ចូលតំបន់អង្គរ កាលពីថ្ងៃទី១៤ ធ្នូ ឆ្នាំ១៩៩២ និងប្រាសាទព្រះវិហារកាលពីថ្ងៃទី ៧ ខែកក្កដា ឆ្នាំ២០០៨ជាបេតិកភណ្ឌពិភពលោក ព្រមទាំងការចុះបញ្ជីរបាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យ កាលពីថ្ងៃទី ៧ ខែវិច្ឆកា ឆ្នាំ ២០០៣ និងល្ខោនស្រមោលស្បែកធំ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០០៥ ជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ ។

បច្ចុប្បន្ន កម្ពុជាកំពុងត្រៀមរៀបចំឯកសារដោយមានការជួយជ្រោមជ្រែងពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ក្នុងការស្នើសុំដាក់បញ្ចូលក្រុមប្រាសាទសម្បូណ៌ព្រៃគុកជាបេតិកភណ្ឌពិភព-លោក និងក្បាច់គុនល្បុក្កតោ និងល្បែងទាញព្រ័ត្រជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្ស-ជាតិថែមទៀត ។

ប្រាសាទសម្បូណ៌ព្រៃគុក ដែលជាសំណង់ស្ថាបត្យកម្មដ៏វិសេសវិសាលស្ថាបនាឡើងនៅសតវត្សទី ៧ ហើយដែលបច្ចុប្បន្នមួយផ្នែកធំកំពុងប្រឈមនឹងការខូចខាតយ៉ាងធ្ងន់ធ្ងរផង នោះសក្ដិសមនឹងត្រូវបានការដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោកណាស់ ។

ចំណែកឯក្បាច់គុនល្បុក្កតោវិញ បុព្វបុរសខ្មែរបានបង្កើត និងបានផ្ទេរចំណេះជំនាញក្បាច់គុនដ៏អស្ចារ្យមួយបែបនេះ ដើម្បីការពារខ្លួន ការពារសហគមន៍ និងការពារប្រទេសជាតិ ជាច្រើនសតវត្សមកហើយ ដែលយើងឃើញមានជាតឹកតាងបង្ហាញតាមចម្លាក់ជញ្ជាំងប្រាង្គប្រាសាទនានា និងរូបគំនូរជាអាទិ៍ នៅព្រះវិហារនៃវត្តកំពង់ត្រឡាចលើក្នុងខេត្តកំពង់ឆ្នាំងជាដើម ។ ចម្លាក់ និងគំនូរទាំងនោះសុទ្ធតែបង្ហាញអំពីការប្រើដៃជើងប្រកួតគ្នា ។

រីឯល្បែងទាញព្រ័ត្រ ជាល្បែងប្រពៃណីដ៏សំខាន់មួយប្រភេទដែលខ្មែរនិយមលេងនៅក្នុងពិធីបុណ្យចូលឆ្នាំ និងពេលខ្លះគេនិយមលេងក្នុងពិធីបុណ្យម្យ៉ាងដែលបងប្អូនអ្នកស្រុកសៀមរាប ហៅថាបុណ្យឆ្លងចែត្រ ។ ល្បែងនេះ គេលេងជាការកំសាន្តផង និងជាកិច្ចក្នុងពិធីផង ។ ការលេងនោះ គឺគេកំណត់យកមនុស្សពីរក្រុម ជាពិសេសប្រុសម្ខាងស្រីម្ខាងប្រកួតគ្នាទាញខ្សែព្រ័ត្រយកឈ្នះចាញ់ ។ ទន្ទឹមនេះ ការលេងកំសាន្តក៏ជាកិច្ចពិធីដែរ ពោលគឺក្នុងន័យផ្ដាច់ឆ្នាំចាស់និងរដូវនៃការដាំដុះធ្វើស្រែស្រូវឆ្នាំថ្មី ។ ក្នុងការស្នើសុំដាក់បញ្ចូលល្បែងនេះទៀតសោត កម្ពុជាពុំមែនធ្វើតែម្នាក់ឯងនោះទេ គឺមានការចូលរួមពីបណ្ដាប្រទេសមួយចំនួនទៀត ដែលមានល្បែងបែបនេះដូចគ្នា ហើយក៏មានចេតនានឹងចុះក្នុងបញ្ជីបេតិកភណ្ឌអរូបីនៃមនុស្សជាតិរួមគ្នាផងដែរ ។ ប្រទេសទាំងនោះរួមមាន សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋហ្វីលីពីន និងសាធារណ



*របាំក្បាច់បុរាណ ឬរបាំព្រះរាជទ្រព្យ ត្រូវបានដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក*





*ប្រាសាទសម្បូរណ៍ព្រៃគុក ក្បាច់គុនល្បុក្កតោ និងល្បែងទាញព្រ័ត្រជាបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិកំពុងត្រៀមរៀបចំឯកសារ ដោយមានការជួយជ្រោមជ្រែងពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ក្នុងការស្នើសុំដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក*

រដ្ឋសង្គមនិយមវៀតណាម ។ ការសហការរួមគ្នាក្នុងការ រៀបចំឯកសារនេះ គឺសបញ្ជាក់ឱ្យឃើញនូវការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ដោយមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាសេនាធិការក្នុងការរឹតចំណងសាមគ្គីភាពជាមួយបណ្ដាប្រទេសឯទៀតលើវិស័យវប្បធម៌ ។

សព្វថ្ងៃ បេតិកភណ្ឌវប្បធម៌ជាតិកំពុងក្លាយ



*ល្ខោនស្រមោលស្បែកធំ*

ជាចលករដ៏មានប្រសិទ្ធភាព ក្នុងការរួមចំណែកអភិវឌ្ឍ សង្គម សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន តាមរយៈការទាក់ទាញនូវកំណើនភ្ញៀវទេសចរ និង ការពង្រីកទីផ្សារការងារជូនប្រជាពលរដ្ឋផងដែរ ។ ជាក់ស្ដែងក្នុងឆ្នាំ ២០១៣ កន្លងទៅនេះ ព្រះរាជាណាចក្រកម្ពុជា ទទួលបានភ្ញៀវទេសចរដល់ទៅ ៤ លាន ២ សែន នាក់ ហើយចំនួនភ្ញៀវទេសចរនឹងកើនឡើងថែមទៀតក្នុងឆ្នាំបន្តបន្ទាប់ ។

ដូច្នេះការដាក់បញ្ចូល និងការត្រៀមដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌ជាតិជាបេតិកភណ្ឌពិភពលោក និងការចុះបញ្ជីបេតិកភណ្ឌអរូបីនៃមនុស្សជាតិ ព្រមទាំងកិច្ចសហប្រតិបត្តិការ និងការចូលរួមនៃគ្រប់កម្លាំងក្នុងសង្គម ក្នុងការអភិរក្ស និងអភិវឌ្ឍសម្បត្តិវប្បធម៌ជាតិ គឺជាកត្តាដ៏សំខាន់មិនអាចខ្វះបាន ដើម្បីធានាចីរភាពនៃបេតិកភណ្ឌវប្បធម៌ជាតិយើង និងជំរុញដំណើរការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ។/



*ចម្លាក់ផ្ដែរ កូរសមុទ្រទឹកដោះ និងល្បែងប្រពៃណីទាញព្រ័ត្រ*



តមកពីទំព័រទី ៥

មជ្ឈដ្ឋានអគតិមួយចំនួន ឆ្លៀតឱកាសធ្វើការអុជអាល ញុះញង់ចង់ឱ្យពលករធ្វើបាតុកម្មប្រឆាំងរាជរដ្ឋាភិបាលទៅវិញ ។ ពួកគេបំផុសឱ្យពលករចងកំហឹងនឹងអាជ្ញាធរដែនដីដែលកំពុងតែដុតដៃដុតជើងជួយពលករឱ្យរួចផុតពីការលំបាក ។ គេឆ្លៀតប្រើឱកាសនេះប៉ុនប៉ងរកចំណេញខាងនយោបាយ ដោយមិនបានគិតគូរទៅដល់សុខទុក្ខ និងផលប្រយោជន៍របស់បងប្អូនពលករយើងឡើយ ។ ប៉ុន្តែបងប្អូនពលករមិនជឿតាមការញុះញង់ទាំងនោះទេ ។ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់សម្ដេចតេជោ **ហ៊ុន សែន** បានដោះស្រាយបញ្ហាថៃដន្យនេះយ៉ាងទាន់ពេលវេលា និងមានប្រសិទ្ធភាពជាមួយនឹងប្រតិបត្តិការដ៏ឆាប់រហ័សតាំងពីការចាប់ផ្ដើមរហូតដល់បញ្ចប់ ដែលបានឆ្លុះបញ្ចាំងច្បាស់នូវសមត្ថភាពរបស់រាជរដ្ឋាភិបាល ។

ឆ្លងតាមសភាពការណ៍នេះបានផ្ដល់ជាមេរៀនសម្រាប់ពលករយើងដែរ ដែលមានបំណងធ្វើចំណាកស្រុក ព្រោះថាការចាកចេញពីគ្រួសារ ផ្ទះសម្បែង ភូមិដ្ឋានទៅធ្វើការនៅឯទីឆ្ងាយពិតជាជួបការលំបាក ហើយបើទៅធ្វើការដោយមិនស្របច្បាប់នោះគឺកាន់តែមានហានិភ័យថែមទៀត ។ បើយើងនៅតស៊ូធ្វើការនៅលើទឹកដីរបស់យើង ទោះជាបានកម្រៃទាបជាងប្រទេសគេបន្តិចមែន ប៉ុន្តែយើងក៏មិនជួបនូវការប្រមាថមាក់ងាយ ការធ្វើទារុណកម្ម និងការរំលោភបែបនេះដែរ ។ ការងារនៅមានច្រើនណាស់ក្នុងប្រទេសយើង បងប្អូនពលករអាចស្វែងរកឱកាសការងារបាននៅគ្រប់ទីកន្លែង ជាពិសេសតាមរយៈមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់ រាជធានី-ខេត្តនីមួយៗ ។ ធ្វើការក្នុងស្រុកនៅបានរួមចំណែកដោយផ្ទាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិយើងថែមទៀត ។

ខ្មែរយើងមានពាក្យទំនៀមមួយឃ្លាថា "ជួញជិតប្រសើរជាងជួញឆ្ងាយ " ។/




# តើផ្លេកបន្ទោរ ផ្គរ រន្ទះ កើតឡើងយ៉ាងដូចម្តេច ?





មានប្រជាជនច្រើនជាង ៥០ នាក់ ដែលបានស្លាប់ និងរបួសដោយសារផ្លេកបន្ទោរ ផ្គរ រន្ទះជារៀងរាល់ឆ្នាំក្នុងព្រះរាជាណាចក្រកម្ពុជា ។

ផ្លេកបន្ទោរ ផ្គរ រន្ទះ គឺជាអគ្គីសនីធម្មជាតិ ដែលត្រូវបញ្ជូនចេញទៅប៉ះនឹងអ្វីមួយនៅលើផែនដីដោយឡែកៗពីគ្នា ។ផ្លេកបន្ទោរ ផ្គរ រន្ទះនេះកើតឡើងដោយសារបណ្តុំពពក Cumulonimbus ។ ពពកនេះមានទំហំធំ និងកម្ពស់ខ្ពស់ឈរត្រង់ទៅលើមានពណ៌ខ្មៅ ដែលនៅក្នុងពពកនោះមានដូចជា: រន្ទះភ្លៀងឬព្រិល( កូនដុំទឹកកក) ដែលកំពុងបញ្ជូនចុះមកផែនដី ។

ដូច្នេះ បើសិនជាលោកអ្នកសង្កេតឃើញមានពពក Cumulonimbus ដូចដែលបានរៀបរាប់ខាងលើ សូមមានការប្រុងប្រយ័ត្ន ព្រោះវាអាចបង្កនូវគ្រោះថ្នាក់ផ្សេងៗដូចជា រន្ទះ ជាដើមនៅក្នុងពពកនោះ ។

## ព័ត៌មានផ្លេកបន្ទោរ ផ្គរ រន្ទះ ដែលផ្តល់ដោយនាយកដ្ឋានឧតុនិយម

នាយកដ្ឋានឧតុនិយមសូមជម្រាបជូនជាសាធារណៈអំពីចំណេះដឹង និងវិធីការពារគ្រោះថ្នាក់ដែលអាចកើតមានដោយសារ ផ្លេកបន្ទោរ ផ្គរ រន្ទះ ។

មានជាសម្គាល់ដូច ខាងក្រោមដែលអាច កើតមានរន្ទះ :

- បើសិនសង្កេតឃើញមានពពក ពណ៌ខ្មៅ រសាត់ជិត ឬពីលើ
- បើសិនជាឮស្នូរសំឡេងផ្គរនៅជិត ឬក្បែរ
- បើសិនសង្កេតឃើញមានផ្លេកបន្ទោរ ចាំងភ្លែត
- ព័ត៌មានដែលផ្តល់ដោយនាយកដ្ឋាន ឧតុនិយមនៃក្រសួងធនធានទឹក និងឧតុនិយម ដែលបានប្រកាសពីទីតាំងដែលមានពពក Cumulonimbus ។

ត្រូវរៀបចំការពារដោយខ្លួនឯង ដូចមានរូបភាពបង្ហាញដូចតទៅ :

**ប្រការគួរចៀសវាង ពេលមាន ផ្លេកបន្ទោរ ផ្គរ រន្ទះ**

- មិនត្រូវនិយាយទូរស័ព្ទ នៅពេលឮសំឡេងផ្គរ






- មិនត្រូវអង្គុយនៅ ក្រោមដើមឈើ

- មិនត្រូវជិះម៉ូតូ ឬកង់



- មិនត្រូវអង្គុយក្នុងតង់



# ប្រការត្រូវអនុវត្តពេលមានផ្លេកបន្ទោរ ផ្គរ រន្ទះ



- ត្រូវបន្ទន់ខ្លួនដោយបញ្ឈរជង្គង់ទាំងពីរជិតគ្នា និងយកដៃខ្ទប់ត្រចៀកទាំងសងខាង

- ត្រូវរត់ចេញពីទឹក ឬស្រែ





- នៅខាងក្នុង ឬរត់ចូលទៅក្នុងផ្ទះជាប្រញាប់

- ត្រូវបន្ទន់ខ្លួនឱបក្បាលជង្គង់ និងបិទ ត្រចៀកសងខាង នៅក្រោមបង្គោលភ្លើង





- ក្នុងរថយន្តមានសុវត្ថិភាព តែមិនត្រូវប៉ះ ចង្កូត ឬទ្វារ

- ត្រូវអង្គុយក្នុងតំបន់សុវត្ថិភាពក្នុងផ្ទះ







- ដកឌុយដោតភ្លើង ឬឌុយទូរស័ព្ទ ទុកចម្ងាយ ១ ម៉ែត្រ ពីប្រភពចរន្តអគ្គិសនី ។

*ប្រភពឯកសារ : នាយកដ្ឋានឧតុនិយម នៃក្រសួងធនធានទឹក និងឧតុនិយម សហការជាមួយទីភ្នាក់ងារ សហប្រតិបត្តិការអន្តរជាតិជប៉ុន*









# ទៅកាន់ច្រកអានសេះ ពីគ្មានផ្លូវនឹងទៅជាមានផ្លូវកៅស៊ូឆាប់ៗនេះ

*ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ជាអាទិភាពមួយចំនួនរាជរដ្ឋាភិបាលនីតិកាលទី៤(២០០៩-២០១៣) និងបន្តដោយរាជរដ្ឋាភិបាលនីតិកាលទី ៥ នេះ បានយកចិត្តទុកដាក់ជំរុញការអភិវឌ្ឍតំបន់ព្រំដែននៃប្រទេស ជាពិសេសវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ ស្ពាន និងវិស័យដទៃទៀតដែលទាក់ទងនឹងជីវភាពរស់នៅផ្ទាល់ប្រចាំថ្ងៃរបស់ប្រជាជន ។ មហិច្ឆតារបស់រាជរដ្ឋាភិបាលចង់ប្រែក្លាយតំបន់ព្រំដែនដែលមុននេះជាតំបន់អសន្តិសុខឱ្យទៅជាតំបន់ដែលមានសន្តិភាព ស្ថិរភាព និងអភិវឌ្ឍន៍ ។*

*ផ្ដើមចេញពីការកំណត់អាទិភាពដូច្នេះ គេបានកត់សម្គាល់ឃើញថាតំបន់ព្រំដែនកម្ពុជា-ថៃនាទិសឧត្តរពាយ័ព្យនិងបស្ចឹមជាបណ្ដើរៗបានផ្លាស់ប្ដូរស្ថានភាពនិងមុខមាត់ពីតំបន់ដាច់ស្រយាលព្រៃរហោស្ថាន តំបន់គំរាមដោយគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ គ្មានផ្លូវ...និងមានមនុស្សរស់នៅតិចតួច ទៅជាតំបន់សេដ្ឋកិច្ច និងកសិកម្ម ។ ប្រជាជនមានភាពមមាញឹកជាងមុនក្នុងរបររកស៊ីផ្សេងៗ ជាមួយនឹងការរស់នៅកាន់តែប្រសើរឡើងទាំងស្មារតី និងសម្ភារៈ ។ តំបន់ជាច្រើនបានចាប់ផ្ដើមមានមនុស្សរស់នៅកុះករ មានផ្លូវខ្វាត់ខ្វែង ។ ផ្លូវដែលពីមុនគ្រាន់តែជាលំនាំផ្លូវលំឬដែលគេហៅថាជាផ្លូវដើរ បច្ចុប្បន្នយ៉ាងហោចណាស់ក៏ជាផ្លូវក្រាលក្រួសក្រហមដែរ ។*





*លោកនាយឧត្ដមសេនីយ៍ **ខ្វាន់ សាវម** និងគណៈប្រតិភូអន្តរក្រសួង អញ្ជើញពិនិត្យសកម្មភាពកងកម្លាំងវិស្វកម្មកំពុងបញ្ជាគ្រឿងចក្រស្ថាបនាផ្លូវក្រាលកៅស៊ូពីត្រពាំងសង្កែ ឆ្ពោះទៅកាន់ស្រះម្លិះ ក្នុងស្រុកជាំក្សាន្ត ខេត្តព្រះវិហារ*

កាលពីដើមខែកក្កដា ឯកឧត្ដមនាយឧត្ដមសេនីយ៍ **ខ្វាន់ សាវម** អគ្គមេបញ្ជាការរង មេបញ្ជាការកងកម្លាំងវិស្វកម្មនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ រួមជាមួយប្រតិភូ អន្តរក្រសួង ដោយមានផ្នែកជំនាញវិស្វកម្មក្រសួងសាធារណការ និងដឹកជញ្ជូន ដែលជាក្រសួងអាណាប័កដើមខ្សែ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចុះទៅពិនិត្យមើលដោយផ្ទាល់តាមបណ្ដាការដ្ឋាន និងសមិទ្ធផលមួយចំនួនដែលកងកម្លាំងវិស្វកម្មនៃអគ្គបញ្ជាការដ្ឋានសម្រេចបានក្នុងការកសាងបណ្ដាញផ្លូវគមនាគមន៍ប្របខ្សែក្រវ៉ាត់ព្រំដែនកម្ពុជាថៃ នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។ នោះ គឺការដ្ឋាននៃការស្ថាបនាផ្លូវក្រាលកៅស៊ូពីទីប្រជុំជនស្រុកជាំក្សាន្តឆ្ពោះទៅកាន់ច្រកអានសេះ( ច្រកព្រំដែន) ដែលមានប្រវែងជាង ២២ គីឡូម៉ែត្រ ។ កំណាត់ផ្លូវនេះអាចនិយាយបានថាជាផ្លូវប្រវត្តិសាស្ត្រដំបូងនៃតំបន់នេះ ពីព្រោះកន្លងមករាប់ទាំងបណ្ដាផ្លូវមកកាន់ទីប្រជុំជនជាំក្សាន្ត និងវិថីទៅកាន់អានសេះនេះផង គឺពុំដែលមានផ្លូវធំទូលាយដូចគ្រានេះឡើយ ។ វាក៏មានផ្លូវមួយខ្សែទៀតប្រវែងជាង២៦គីឡូម៉ែត្រពីឃុំត្រពាំងសង្កែ( ស្រុកជាំក្សាន្ត( ទៅស្រះម្លិះ( ស្រុកជាំក្សាន្ត) ។

ឈរនៅត្រង់ចំណុចផ្លូវបំបែកនៃផ្លូវជាតិលេខ ៦២ ( កំពង់ធំ-ព្រះវិហារ អតីតផ្លូវជាតិលេខ ១២) ក្នុងភូមិសាស្ត្រឃុំត្រពាំងសង្កែ ភ្ជាប់ជាមួយនឹងផែនទីមួយផ្ទាំង លោកនាយឧត្ដមសេនីយ៍ បានបង្ហាញពីតម្រោយផ្លូវមួយចំនួនដែលកងកម្លាំងវិស្វកម្មនៃអគ្គបញ្ជាការដ្ឋានបាន និងកំពុងធ្វើ និងបណ្ដាញផ្លូវមួយចំនួនទៀតដែលបានស្ថាបនារួចរាល់នាពេលកន្លងទៅ ។ លោកបានបញ្ជាក់ថា មានផ្លូវចំនួនពីរក្នុងចំណោមផ្លូវសំខាន់ៗដទៃទៀតដែលកងទ័ពកំពុងធ្វើ គឺផ្លូវពីឃុំត្រពាំងសង្កែទៅកាន់ចំណុចស្រះម្លិះ( ស្រះឆ្អេះ) ដែលមានប្រវែងជាង ២៦ គីឡូម៉ែត្រ និងផ្លូវពីទីប្រជុំជនស្រុកជាំក្សាន្តទៅកាន់ច្រកអន្តរជាតិអានសេះដែលមានប្រវែងជាង ២២ គីឡូម៉ែត្រ ។ ផ្លូវទាំងពីរនេះនឹងពង្រីកពីផ្លូវលំឱ្យទៅជាផ្លូវក្រាលកៅស៊ូដែលមានទទឹង ៩ ម៉ែត្រ ក្នុងនោះសាច់ចាក់ក្រាលកៅស៊ូទំហំ ៧ ម៉ែត្រ ។ ផ្លូវនេះកំពុងធ្វើដោយកងស្ថាបនាផ្លូវលេខ ៧១៨ របស់បញ្ជាការដ្ឋានវិស្វកម្មអគ្គបញ្ជាការ ។





*គណៈប្រតិភូអន្តរក្រសួងពិនិត្យស្ថានភាពផ្លូវឡើងភ្នំអានសេះ ដែលមានសភាពតូចចង្អៀត និងបាំងដោយផ្ទាំងថ្មធំៗ*

លោកបន្តថាផ្លូវទៅកាន់ស្រះម្ទិះគឺជាផ្លូវតភ្ជាប់គ្នាក្នុងតំបន់ព្រំដែននៃទិសខេត្តព្រះវិហារ ជាផ្លូវយុទ្ធសាស្ត្រតភ្ជាប់ផ្ទៃក្នុង។ ផ្លូវនេះចាប់ពីត្រពាំងសង្កែកាត់តាមទីប្រជុំជនស្រុកជាំក្សាន្តដែលមានប្រវែង២៦,៤០០គីឡូម៉ែត្រ។ បច្ចុប្បន្នផ្លូវនេះកំពុងដំណើរការចាក់ក្រាលកៅស៊ូ ដែលមានទទឹង ៧ ម៉ែត្រលើសាច់ដីផ្លូវសុទ្ធចំនួន ៩ ម៉ែត្រ។ ផ្លូវនេះបានចាប់ផ្ដើមធ្វើនៅឆ្នាំ ២០១០ ដោយដំបូងគឺក្រាលក្រួសក្រហម។មកដល់ឆ្នាំ២០១៣ទើបបានដំណើរការចាក់ក្រាលកៅស៊ូជាជំហានៗ។លោកបានបន្តថាផ្លូវមួយខ្សែនេះជាផ្លូវចាស់យូរមក ហើយប៉ុន្តែជាផ្លូវលំតូច ឬដែលគេហៅថាជាផ្លូវដីរមានសភាពតូចចង្អៀត ពិបាកក្នុងការធ្វើចរាចរណ៍ ។

ដោយសម្លឹងទៅរកអ្វីដែលលេចចេញជារូបរាងហើយនោះ លោកបានបញ្ជាក់ថា ពេលនេះមិនដូចគ្រាមុនឡើយ ការធ្វើដំណើរគេមិនបាច់សួរគ្នាថាតើទៅរួចឬអត់?នោះឡើយ ប្រជាជនក្នុងតំបន់ក៏ដូចជាមកពីតំបន់ផ្សេងៗ អាចធ្វើដំណើរដោយមិនមានការព្រួយបារម្ភ។

ដោយឡែកកំណាត់ផ្លូវមួយខ្សែទៀតគឺពីទីប្រជុំជនស្រុកជាំក្សាន្តទៅកាន់ច្រកអានសេះ។ផ្លូវនេះចេញពីចំណុចផ្លូវបំបែកទីប្រជុំជនជាំក្សាន្តឆ្ពោះទៅកាន់កំពូលភ្នំ ច្រកទ្វារអន្តរជាតិអានសេះដែលមានចម្ងាយផ្លូវ ប្រវែង ២២,៦៦០ គីឡូម៉ែត្រ។

សូមបញ្ជាក់ថា តំបន់អានសេះនេះគឺជាតំបន់មួយដាច់ស្រយាលស្ថិតនៅលើកំពូលភ្នំដងរែកដែលមានរយៈកម្ពស់ពី៦០០ទៅជាង ៧០០ ម៉ែត្រ។ ពីអតីតកាលប្រជាជនសាមញ្ញពុំដែលធ្វើដំណើរទៅដល់ទីនោះឡើយ ក្រៅតែពីកងឯកភាពការពារព្រំដែនដែលមានភារកិច្ចឈរជើងការពារបូរណភាពទឹកដី។មុននេះដើម្បីទៅកាន់ទីនោះ ការធ្វើដំណើរត្រូវប្រឈមនឹងឧបស័គ្គជាច្រើន ដោយសារពុំមានផ្លូវនិងជាតំបន់សម្បូរទៅដោយគ្រាប់មីនគ្រប់ប្រភេទ។

ប៉ុន្តែប្រមុខរាជរដ្ឋាភិបាលបានប្ដេជ្ញាកែប្រែស្ថានភាពនៅទីនោះបន្ទាប់ពីច្រកមួយនេះ (អានសេះ) ត្រូវបានដាក់ឱ្យទៅជាច្រកអន្តរជាតិជាមួយប្រទេសថៃនាឆ្នាំ ២០១២ ។ ច្រកនេះស្ថិតក្នុងស្រុកជាំក្សាន្តនៅជាប់ជាមួយនឹងស្រុកណាំយឺន ខេត្តអ៊ូប៊ុន ប្រទេសថៃ។

ពាក់ព័ន្ធទៅនឹងការងារស្ថាបនាផ្លូវទៅកាន់ច្រកអានសេះ ឯកឧត្ដមនាយឧត្ដមសេនីយ៍ **ខ្វាន់ ស៊ារម** បានបញ្ជាក់ថា កំណាត់ផ្លូវមួយនេះអាចចាត់ទុកថាជាផ្លូវដែលលំបាកក្នុងការសាង សង់ដោយសារតែស្ថានភាពភូមិសាស្ត្រ និងពីមុនពុំមានតម្រាយផ្លូវទេ។ ផ្លូវនេះនឹងត្រូវធ្វើដូចផ្លូវពីត្រពាំងសង្កែទៅស្រះម្ទិះដែរ គឺមានទទឹង ៩ ម៉ែត្រ ហើយនឹងចាក់ក្រាលកៅស៊ូទទឹងប្រវែង ៧ ម៉ែត្រ។ ការធ្វើផ្លូវនេះដំបូងក្នុងអំឡុងឆ្នាំ២០១១-២០១២ ដោយកងកម្លាំងវិស្វកម្មកងឯកភាពស្ថាបនាផ្លូវលេខ ៧១៨ និងកងឯកភាពស្ថាបនាស្ពានលេខ ៧១៥។ ការស្ថាបនាបានចាប់ផ្ដើមត្រួសត្រាយ និងលើកតួផ្លូវសាងសង់ស្ពាន និងដាក់លូ។ ប៉ុន្តែដោយត្រូវរងគ្រោះទឹកជំនន់ការដ្ឋាននេះបានផ្អាកជាបណ្ដោះអាសន្ន ហើយទើបនឹងចាប់ផ្ដើមធ្វើជាថ្មីនៅឆ្នាំ២០១៣។ជាលទ្ធផលមកដល់ពេលនេះ សម្រេចបានលើកតួ ផ្លូវចាក់ក្រាលក្រួសក្រហមបានប្រវែង ១៨,៩០០ គីឡូម៉ែត្រ សាងសង់ស្ពានបាន ៣ កន្លែង ប្រវែងសរុប ៧៥ ម៉ែត្រ ដាក់ដាឡ ៩ កន្លែង ប្រវែងសរុប ៦០ ម៉ែត្រ និងដាក់លូ ២៥ កន្លែង ព្រមទាំងឈូសសម្រួលផ្លូវឡើងទៅចំណុចកំពូលភ្នំអានសេះបានប្រវែង៣៧៦០ម៉ែត្រ។

ដើម្បីបង្កើនសន្ទុះការងារ ឯកឧត្ដមនាយឧត្ដមសេនីយ៍មេបញ្ជាការកងកម្លាំងវិស្វកម្មបានដាក់ចេញនូវបទបញ្ជាឱ្យបណ្ដាកងឯកភាពពាក់ព័ន្ធបន្ថែមគ្រឿងចក្រធុនធ្ងន់សំដៅបង្កើនល្បឿនការងារស្ថាបនាផ្លូវឡើងកំពូលភ្នំអានសេះ។ បច្ចុប្បន្នគ្រឿងចក្រធុនធ្ងន់ជាច្រើនគ្រឿងត្រូវបានបញ្ជូនជាបន្តបន្ទាប់ទៅកាន់ការដ្ឋាន។

ឯកឧត្ដម **ខ្វាន់ ស៊ារម** បានបញ្ជាក់ថាការអភិវឌ្ឍនៅតំបន់ព្រំដែន មិនត្រឹមតែសំដៅលើកកម្ពស់ជីវភាពរបស់ប្រជាជននៃប្រទេសទាំងពីរតែប៉ុណ្ណោះទេ ប៉ុន្តែវាបានផ្សារភ្ជាប់ទៅនឹងភារកិច្ចការពារបូរណភាពទឹកដីប្រកបដោយប្រសិទ្ធភាពផងដែរ។ លោកបានសាទរទៅនឹងការដកថយរបស់កងយោធាថៃ ដែលបានបញ្ឈប់ការរារាំងដល់សកម្មភាពការងារ





*គណៈប្រតិភូអន្តរក្រសួងពិនិត្យសកម្មភាពក្នុងការពង្រីកបន្ថែមតួផ្លូវឡើងកំពូលភ្នំអានសេះ និងទីតាំងស្តូបរូបសំណាកលោកតាអ៊ុំ នាបច្ចុប្បន្ន*

របស់កងកម្លាំងវិស្វកម្ម ក្នុងការបំពេញភារកិច្ចរបស់ខ្លួននាបរិវេណខាងមុខរូបសំណាកលោកតាអ៊ុំ ដែលឈមនឹងច្រកទ្វារអន្តរជាតិកម្ពុជា-ថៃ ។

លោកមេបញ្ជាការរងកងឯកភាពស្ថាបនាស្ពានលេខ ៧១៥ ដែលប្រចាំការជាប់លាប់នៅការដ្ឋានធ្វើផ្លូវអានសេះបានបញ្ជាក់ឱ្យដឹងថា បន្ទាប់ពីភាគីទាំងពីរកម្ពុជា ថៃ បានព្រមព្រៀងគ្នា បានធ្វើឱ្យស្ថានការណ៍តំបន់ព្រំដែនច្រកអានសេះកាន់តែមានភាពប្រសើរឡើង ។ កងកម្លាំងវិស្វកម្មក៏បានដំណើរការប្រើគ្រឿងចក្រឈូសឆាយ កែលម្អផ្លូវនាប៉ែកខាងមុខរូបសំណាកលោកតាអ៊ុំជាប់ទីផ្សារអានសេះដែលសម្បូរទៅដោយជង្ហុកធំៗ ឱ្យទៅជាផ្លូវក្រួសក្រហម ដែលអាចឱ្យរថយន្តធុនធ្ងន់បើកបរបានដោយសុវត្ថិភាពនាពេលបច្ចុប្បន្ន ។ លោកមេបញ្ជាការរងក៏បានបន្ថែមឱ្យដឹងទៀតថា សម្រាប់ការលក់ដូររបស់ប្រជាពលរដ្ឋក្នុងផ្សារអានសេះមុខច្រកទ្វារអន្តរជាតិ( ក្នុងដីកម្ពុជា) បានបើកឱ្យដំណើរការពីរថ្ងៃក្នុងមួយសប្តាហ៍ គឺថ្ងៃអង្គារ និងថ្ងៃព្រហស្បតិ៍ ។ ក្នុងរយៈពេលពីរថ្ងៃនេះប្រជាជននៃប្រទេសទាំងពីរអាចឆ្លងកាត់ព្រំដែនទៅវិញទៅមកបាន ។ បន្ថែមពីលើនេះភាគីថៃបានអនុញ្ញាតឱ្យរថយន្តគ្រប់ធុនរបស់ក្រុមហ៊ុនវិនិយោគតំបន់អានសេះចេញចូលដឹកសម្ភារៈសំណង់គ្រប់ប្រភេទឆ្លងកាត់ជារៀងរាល់ថ្ងៃបាន ។

ដោយងាកមករកទីប្រជុំជនស្រុកជាំក្សាន្ត ក៏ដូចជាប្រជាជនដែលរស់នៅតំបន់ក្បែរនឹងព្រំដែនមួយនេះបងប្អូនបានសម្តែងនូវក្តីរំភើប និងរីករាយចំពោះការអភិវឌ្ឍនៅទីនោះពិសេស គឺផ្លូវថ្នល់ដែលកំពុងធ្វើនាពេលនេះ ។ ខណៈដែលប្រតិភូអន្តរក្រសួងចុះទៅដល់ ទាំងមន្ត្រីអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់របស់ស្រុកជាំក្សាន្ត ក៏ដូចជាប្រជាជនក្មេងចាស់ប្រុស ស្រី ដែលបាននាំគ្នាមកអបអរសកម្មភាពកងកម្លាំងវិស្វកម្ម ។ ម្នាក់ៗបានជម្រាបគណៈប្រតិភូនិងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលដែលបានផ្តល់ចំណងដៃផ្លូវកៅស៊ូមួយខ្សែ នេះ ពីព្រោះកន្លងទៅប្រជាជនរស់នៅតំបន់នោះពុំដែលមានផ្លូវកៅស៊ូដូចពេលនេះឡើយ ។

អ្វីដែលគួរឱ្យកត់សម្គាល់ផងដែរ ទន្ទឹមនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធផ្លូវត្រូវបានស្តារ និងស្ថាបនាជាបន្តបន្ទាប់នោះ នៅអមសងខាងផ្លូវគេបានឃើញយ៉ាងប្រត្យក្សនូវចំនួនគេហដ្ឋានថ្មីៗត្រូវបានសង់ពីបេតុងប្រក់ក្បឿងមានការកើនឡើងជាបន្តបន្ទាប់ ជំនួសឱ្យផ្ទះដែលមុនភាគច្រើនជាកូនខ្ទម ជាផ្ទះឈើធម្មតាប្រក់ស័ង្កសី ។ភូមិឃុំធ្លាប់តែមានសភាពស្ងាត់ជ្រងំ បច្ចុប្បន្ន បានជំនួសទៅដោយទីផ្សារដែលមានសភាពអ៊ូអរ ។ ទាំងនេះ អាស្រ័យដោយមានប្រព័ន្ធផ្លូវគមនាគមន៍ខ្វាត់ខ្វែងភ្ជាប់ពីតំបន់មួយទៅរកតំបន់ផ្សេងៗទៀត ។



*ប្រជាជនស្រុកជាំក្សាន្តឡើងទៅទិញទំនិញនៅផ្សារច្រកអានសេះ*

ផ្សារជាំក្សាន្តមានទំនិញលក់ដូរគ្រប់បែបយ៉ាងមិនចាញ់ទីប្រជុំជនដទៃទៀតឡើយ ហើយទំនិញ និងសម្ភារៈប្រើប្រាស់មួយចំណែកធំ ត្រូវបាននាំចូលមកតាមច្រកទ្វារព្រំដែនអន្តរជាតិអានសេះទៀតផង ។ អាជីវករដែលលក់ដូរក្នុងផ្សារនេះបានបញ្ជាក់ថា សូមអរគុណគណបក្សប្រជាជនកម្ពុជាអរគុណប្រមុខរាជរដ្ឋាភិបាលដែលបានយកចិត្តទុកដាក់ដល់ការរស់នៅរបស់ប្រជាជន និងអភិវឌ្ឍតំបន់នេះ ។/




# អបអរសាទរ ថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា



*( បទពាក្យ ៧ )*

- ហុកសិបបីឆ្នាំកន្លងទៅ យើងចងចាំនៅគ្រប់អង្គា
 គឺថ្ងៃបង្កើតបក្សប្រជា ជនកម្ពុជាដ៏ថ្លាថ្លៃ ។
- ទីម្ភៃប្រាំបីមិថុនា ប្រវត្តិពិស្តារខ្មែរពូតដៃ
 ទសវត្សហាមួយឥតកាឡៃ ប្រសូតបក្សថ្លៃរួមកម្លាំង ។
- ក្រោកឈរតស៊ូប្តូរឆន្ទៈ ពុះពារឧបសគ្គស៊ូគ្រតតាំង
 លះបង់ឈាមស្រស់ស្មោះចូលច្បាំង ប្រយុទ្ធប្រឆាំងនឹមត្រួតត្រា ។
- ច្រើនដំណាក់កាលកន្លងទៅ បក្សផ្សារភ្ជាប់នៅនឹងប្រជា
 ដឹកនាំរំដោះព្យុះសង្គ្រា បង្ក្រាបខ្មាំងមារបានជោគជ័យ ។
- វាយផ្តួលរំលំសង្គមក្បត់ របបជួរចត់កាប់ប្រល័យ
 ធ្វើពលិកម្មដ៏ថ្លាថ្លៃ ដោយបក្សឈ្លាសវៃរំដោះជាតិ ។
- ប្រាំពីរមករាចិតប្រាំបួន ជោគជ័យផ្ទួនៗបន្តទៀត
 បក្សផ្តើមការពារកសាងជាតិ អភិវឌ្ឍឥតឃ្លាតជាជំហាន ។
- ពីគំនរផេះក្លិនឆ្អេះឆ្អាប ពីក្រដុនដាបរស់អត់ឃ្លាន
 ក្លាយជាហ៊ឺហាមានធនធាន មានវត្តផ្ទាល់ស្ពានមានសាលា ។
- មានសន្តិភាពសេរីភាព ជឿនលឿនពេញព្រៀបគ្រប់ចលនា
 ដោយគោលនយោបាយថ្លៃថ្លា មាគ៌ាចេស្តាបក្សដឹកនាំ ។
- បក្សប្រជាជនកម្ពុជា បក្សមហិមាបក្សរឹងមាំ
 បក្សមានគុណធ្ងន់បក្សថែទាំ មានបក្សដឹកនាំជាតិរុងរឿង ។

ដោយលោក *សុខ សុធន*



### ពិសេស ត្រង់ណា

នាយម៉ែន និងនាងសើ បណ្តើរគ្នាលេងតាមឆ្នេរសមុទ្រឃើញប្រុសៗនៅទីនោះងាកសម្លឹងមើលនារីដ៏ស្រស់ស្អាតម្នាក់ស្លៀកពាក់ម៉ៃយ៉ូក្រណាត់ស្តើងឆ្នូតសាច់ច្បាស់ក្រឡែតកំពុងលេងទឹក។

នាងសើសួរប្តី :

- នាងនោះពិសេសត្រង់ណាបានជាប្រុសៗសម្លឹងនាងសម្បើមម្ល៉េះ ?

នាយម៉ែន សើចញឹមៗឆ្លើយ :

- បងក៏មិនដឹងដែរ ចាំបងទៅជិតនាងពិនិត្យមើលឱ្យច្បាស់ តើ នាងពិសេសត្រង់ណាខ្លះ ។

### គ្រវែងស្អី ?

នាសម័យសង្គ្រាមទាហានបម្រុងម្នាក់ ដែលមានរ៉ុស្បែពេញខ្លួនត្រូវបានគេសែងមកដាក់លើគ្រែនៅមន្ទីរពេទ្យយោធាកន្លែងអ្នករបួស ។

យោធិនត្រូវរបួសម្នាក់សម្រាកនៅគ្រែក្បែរងាកមកសួរ :

- ម៉េចត្រូវរបួសច្រើនម្ល៉េះត្រូវគ្រាប់ផ្លោងមែនទេ ?

- មិនមែនគ្រាប់ផ្លោងទេ គឺគ្រាប់បែកដៃហើយជាគ្រាប់របស់ខ្លួនឯងទៅទៀត។ ខ្ញុំឃើញលេណដ្ឋានរបស់ខ្មាំងមួយក៏ស្រវាហូតគ្រាប់បែកពីចង្កេះហើយប្រញាប់កន្ទ្រាក់ដោះកន្លាស់ចេញភ្លាម ទទួលនឹកឃើញកាលកំពុងនៅហ្វឹកហាត់គ្រូប្រាប់ថាកន្ទ្រាក់ដោះកន្លាស់ចេញរួចគ្រវែងសំដៅគោលដៅភ្លាម ។ ប៉ុន្តែគាត់មិនបានប្រាប់ថាគ្រវែងគ្រាប់បែក ឬគ្រវែងកន្លាស់ទេ ដូច្នេះហើយទើបខ្ញុំក្លាយជាអីចឹង។

### ឆ្កែដុះស្នែង

ពេលឃើញឪពុកត្រឡប់ពីធ្វើការមកដល់ផ្ទះកុមារីរ៉ូហ្សាស្ទុះទៅចាប់ដៃហើយប្រាប់

-ប៉ា ប៉ា លោកយាយអត់ដែលស្គាល់គោទេ !

-អេហ៎ កូននិយាយខុសហើយ ! លោកយាយជាកសិករចំនួធ្លាប់ចិញ្ចឹមគោមួយក្រោលរាល់ថ្ងៃ រឿងអីថាលោកយាយមិនស្គាល់គោ ។

-ទេ ខ្ញុំនិយាយមែនណាប៉ា ! ម្សិលមិញខ្ញុំគូររូបគោលើក្រដាសបង្ហាញគាត់មើលគាត់បែរជាសើចហើយនិយាយថាយីអើនៅទីក្រុងឥឡូវមានឆ្កែដុះស្នែងផងហ្ន៎ ។ ហាក៏ បើគាត់ស្គាល់គោហេតុអ្វីពេលឃើញរូបគោរបស់ខ្ញុំ គាត់ថាជាឆ្កែដុះស្នែងទៅវិញ ។

### សាប៊ូមួយដុំ

យុវជនឡាក់ សួរកញ្ញាឡឹងជាសង្សារ

- សប្តាហ៍ក្រោយជាថ្ងៃខួបកំណើតអូនហើយ ។ដល់ពេលនោះតើអូនចង់ឱ្យបងជូនកាដូអី?

- ចាំះអូនចង់បានកាដូដែលអាចប្រើបាននៅដៃត្រចៀកនិងក !

- អូហ៍ បងយល់ហើយ !

ដល់ថ្ងៃខួបកំណើតនាងឡឹងនាយឡាក់បានជូនផ្កាកូលាបមួយបាច់ និងកញ្ចប់មួយតូចល្មមព្រមទាំងនិយាយ

- ជូនពរថ្ងៃខួបកំណើតអូន ។ បងសង្ឃឹមថាអូននឹងបានសប្បាយចិត្ត

- ចាំះអរគុណបង អូនពិតជាស្រស់ស្អាតថែមទៀតដោយសារកាដូរបស់បង ។

និយាយរួច នាងឡឹងលាតកញ្ចប់សន្សឹមៗ។ ក្នុងកញ្ចប់មានសាប៊ូក្រអូបមួយដុំ និងសំបុត្រតូចមួយមានសេចក្តីថា " អូនសម្លាញ់ សាប៊ូនេះមិនត្រឹមតែជួយសម្អាតដៃត្រចៀកនិងកទេអូនអាចប្រើសម្អាតខ្លួនប្រាណទាំងមូលរបស់អូនក៏បានដែរ " ។/

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៥៨

| | | | | |
|---|---|---|---|---|
| ១- | ឯ.ឧ | **កែ គឹមយ៉ាន** | *សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ* | ១០០ ដុល្លារ |
| ២- | ឯ.ឧ | **មិន ឃិន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ* ***ខួន ឌួន*** | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | **ត្រាំ អ៊ីវតឹក** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន* | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ថោង ខុន** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍* | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **ប្រាក់ ចំរើន** | *សមាជិកព្រឹទ្ធសភា* | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **គង់ វិបុល** | *ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **លន់ លឹមថៃ** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម* | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **ជៀង អំ** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង* | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **អូស្មាន ហាស្សាន់** | *ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា* | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **សរ ចំរ៉ុង** | *ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ* | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **ចាំ សុជាតិវង្ស** | *ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ* | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **ឈិត សុខុន** | *អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ* | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **ម៉ម ប៊ុននាង** | *សមាជិកព្រឹទ្ធសភា* | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ម៉ៅ ធនិន** | *អភិបាលនៃគណៈអភិបាលខេត្តពោធិសាត់* | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **អ៊ុន វីរជាតិ** | *រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី* | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **យុ តិរម្យ** | *សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់* | ១០០ ដុល្លារ |
| ១៧- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | ៥០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | ៥០ ដុល្លារ |
| ២១- | ឯ.ឧ | **លឹម គានហោ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក* | ២០០.០០០ ៛ |
| ២២- | ឯ.ឧ | **ម៉ម ប៊ុនហេង** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល* | ៥០ ដុល្លារ |
| ២៣- | ឯ.ឧ | **ជា យ៉ាវ** | *អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា* | ២១៣.៤៧០៛ |
| ២៤- | ឯ.ឧ | **ជូ យិនស៊ីម** | *រដ្ឋលេខាធិការក្រសួងសុខាភិបាល* | ៥០ ដុល្លារ |
| ២៥- | ឯ.ឧ | **អ៊ុក ប្រាថ្នា** | *រដ្ឋលេខាធិការក្រសួងព័ត៌មាន* | ២០០.០០០ ៛ |
| ២៦- | ឯ.ឧ | **ឃឹម សារិទ្ធ** | *ប្រធានគណៈកម្មាធិការគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ* | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | **ប៉ាវ ហាមផាន** | *អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ* | ៥០ ដុល្លារ |
| ២៨- | ឯ.ឧ | **សូ ជុងហួរ** | *ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ* | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **ចាយ បូរិន** | *អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម* | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **នរៈ រតនៈវឌ្ឍនោ** | *រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា* | ២០០.០០០ ៛ |
| ៣១- | ឯ.ឧ | **ឃួន វ៉ានីន** | *រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា* | ៥០ ដុល្លារ |
| ៣២- | ឯ.ឧ | **បូន លឹមហេង** | *អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី* | ២០០.០០០៛ |
| ៣៣- | ឯ.ឧ | **សេង ទៀង** | *ជំនួយការផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ* ***ហ៊ុន សែន*** | ២០០.០០០៛ |
| ៣៤- | ឯ.ឧ | **ម៉ៅ ប៊ុនណារិន** | *សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា* | ១០០.០០០៛ |
| ៣៥- | ឯ.ឧ | **ប៉ាន ប៊ុនធឿន** | *រដ្ឋលេខាធិការក្រសួងផែនការ* | ១០០.០០០៛ |
| ៣៦- | លោកជំទាវ | **ស៊ឹង ស៊ុំយុត** | | ១០០.០០០៛ |
| ៣៧- | ឯ.ឧ | **គឹម ឆា** | *ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង* | ១០០.០០០៛ |
| ៣៨- | ឯ.ឧ | **ប៊ិច សុវណ្ណ** | | ១០០.០០០៛ |
| ៣៩- | ឯ.ឧបណ្ឌិត | **មាស ប៉ូ** | *អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍* | ១០០.០០០៛ |
| ៤០- | លោកជំទាវ | **និត្យ ច័ន្ទតារីន** | *អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់* | ១០០.០០០៛ |
| ៤១- | ឯ.ឧ | **ឆា ច័ន្ទលីដា** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ១០០.០០០៛ |
| ៤២- | ឯ.ឧ | **ម៉ែន វិបុល** | *ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង* | ១០០.០០០៛ |
| ៤៣- | ឯ.ឧ | **ជួន ថេរ៉ាវ៉ាត** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន* | ១០០.០០០៛ |
| ៤៤- | ឯ.ឧ | **ម៉ៅ ឡាំង** | *ទីប្រឹក្សាឯកឧត្ដម* ***ខួន ញឹល*** *អនុប្រធានទី ១ រដ្ឋសភា* | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | **ឆាយ បុទ្ធិសែន** | *អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់* | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | **អ៊ុន ឆាលី** | *សមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណបក្សខេត្តកោះកុង* | ១០០.០០០៛ |
| ៤៧- | លោក | **អោម ចន** | *ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ* | ១០០.០០០៛ |
| ៤៨- | លោក | **សាំ ពិសិដ្ឋ** | *ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ* | ១០០.០០០៛ |
| ៤៩- | លោក | **សុខ វិសាលសម្បត្តិ** | *អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំត្នោត១ ស្រុកស៊ីធរកណ្ដាល ប្រធានក្រុមហ៊ុនសម្បត្តិមហាសាល* | ១០០.០០០៛ |
| ៥០- | លោក | **សារុ រដ្ឋជាតិ** | *មន្ត្រីសាលាខេត្តប៉ៃលិន* | ៧០.០០០៛ |
| ៥១- | លោកជំទាវ | **ខេង សំវ៉ាដា** | *រដ្ឋលេខាធិការក្រសួងកិច្ចការនារី* | ៥០.០០០៛ |
| ៥២- | ឯ.ឧ | **សាយ បូរិន** | *ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី* ***ហេង សំរិន*** | ៥០.០០០៛ |
| ៥៣- | ឯ.ឧ | **សេង គឹមសាន** | *ជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល* ***ជា ស៊ីម*** | ៥០.០០០៛ |
| ៥៤- | ឯ.ឧ | **ពត ចាន់នី** | *សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម* | ៥០.០០០៛ |
| ៥៥- | ឯ.ឧ | **ហេង វណ្ណា** | *សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ* | ៥០.០០០៛ |
| ៥៦- | លោក | **ស៊ាង ចាន់** | *សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ* | ៥០.០០០៛ |
| ៥៧- | លោក | **ឃួន សំបូរ** | *សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ* | ៥០.០០០៛ |
| ៥៨- | លោកជំទាវ | **សឿ ច័ន្ទថា** | | ៥០.០០០៛ |
| ៥៩- | លោក | **ជា វុទ្ធី** | *សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ* | ៥០.០០០៛ |
| ៦០- | លោក | **ហួត ពៅ** | *ប្រធាននាយកដ្ឋាននីតិវិធីនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា* | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៥៨

| | | | | | |
|---|---|---|---|---|---|
| ៦១- | កញ្ញា | ផាង | និតហ្វឺរី | មន្ត្រីក្រសួងទេសចរណ៍ | ៥០.០០០៛ |
| ៦២- | លោក | ង៉ោ | ម៉េងជួន | អភិបាលក្រុងប៉ោយប៉ែត | ៥០.០០០៛ |
| ៦៣- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៤- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ | ៥០.០០០៛ |
| ៦៥- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៦- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ | ៥០.០០០៛ |
| ៦៧- | លោក | ចាប | ឌីណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ | ៥០.០០០៛ |
| ៦៨- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ៤០.០០០៛ |
| ៦៩- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧០- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ | ៤០.០០០៛ |
| ៧១- | គណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម | | | | ៤០.០០០៛ |
| ៧២- | ឯ.ឧ | ស៊ិន | ឧុឌ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៣- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ | ៣០.០០០៛ |
| ៧៤- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ | ៣០.០០០៛ |
| ៧៥- | លោក | ចាន់ | ស៊ុំណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ៣០.០០០៛ |
| ៧៦- | លោក | ឃុ | ពៅ | អភិបាលស្រុកស្វាយចេក | ៣០.០០០៛ |
| ៧៧- | លោក | ទេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ | ៣០.០០០៛ |
| ៧៨- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ៣០.០០០៛ |
| ៧៩- | ឯ.ឧ | ចុង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨០- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨១- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨២- | លោក | លឹម | វីរក្ស | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម | ២០.០០០៛ |
| ៨៣- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ២០.០០០៛ |
| ៨៤- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ២០.០០០៛ |
| ៨៥- | លោក | ជា | គឹមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា | ២០.០០០៛ |
| ៨៦- | លោក | ទូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៨៧- | លោក | ហ៊ុង | ថ្មីន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | ២០.០០០៛ |
| ៨៨- | លោក | ម៉ី | វុធ្ធា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ២០.០០០៛ |
| ៨៩- | លោក | អ៊ុក | គីមអាន | មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២០.០០០៛ |
| ៩០- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ | ២០.០០០៛ |
| ៩១- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ | ១៥.០០០៛ |
| ៩២- | លោក | អ៊ុច | សាវ៉ន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ | ១៥.០០០៛ |
| ៩៣- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា | ១០.០០០៛ |
| ៩៤- | ឯ.ឧ | ប៉ុញ | សច្ចៈ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៥- | លោក | ម៉ី | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម | ១០.០០០៛ |
| ៩៦- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ៩៧- | លោក | មុំ | ប្រុស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៨- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ៩៩- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០០- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០១- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០២- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៣- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្តុះបណ្តាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៤- | លោក | និត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៥- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម | ១០.០០០៛ |
| ១០៦- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៧- | លោក | សូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៨- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១០៩- | លោក | ទីម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១០- | លោក | ណុប | វៀមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១១- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១២- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៣- | លោក | ទូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៤- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៥- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល | ១០.០០០៛ |
| ១១៦- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៧- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៨- | លោក | ឡាច | តីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង | ១០.០០០៛ |
| ១១៩- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង | ១០.០០០៛ |

# មាតិកា

# Contents



ព្រះរាជពិធីដង្ហែ និងតម្កល់
ព្រះបរមអដ្ឋិ
ព្រះបរមរតនកោដ្ឋ

១០



សម្តេចអគ្គមហា
ធម្មពោធិសាល **ជា ស៊ីម**
ប្រគេនទៀនព្រះវស្សាដល់ព្រះសង្ឃ
ចំនួន១២វត្ត នៅរាជធានីភ្នំពេញ

៩



សម្តេចតេជោ **ហ៊ុន សែន**
សម្ពោធស្ពានអាកាសស្ទឹងមានជ័យ
-សេវាដឹកជញ្ជូនសាធារណៈរបស់រាជ
ធានីនឹងមិនយកថ្លៃពីព្រះសង្ឃ .....

១០



## ក្របមុខ

សម្តេចអគ្គមហាសេនាបតីតេជោ
**ហ៊ុន សែន**
និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត
**ប៊ុន រ៉ានី ហ៊ុន សែន**
កាត់ខ្សែបូសម្ពោធស្ពានអាកាស
ស្ទឹងមានជ័យ
(៣១.០៧.២០១៤)



ឯកឧត្តម **សាយ ឈុំ**
អនុប្រធានទី ១ ព្រឹទ្ធសភា
ទទួលជួបសវនាការជាមួយ
ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់

១២


វិចារណកថា : តួនាទីដ៏ធំធេងរបស់គណបក្សប្រជាជនកម្ពុជា ក្នុងការស្វែងរកដំណោះស្រាយនយោបាយជូនជាតិ........ ១

Editorial : CPP's Key Role in Search of National Political Settlement........ ១

⇨ កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយរវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ .... ៣

⇨ ជួញជិតប្រសើរជាងជួញឆ្ងាយ ........ ៥

⇨ សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ........ ១៣

⇨ សរុបព្រឹត្តិការណ៍ : ព្រឹត្តិការណ៍សំខាន់ៗក្នុងខែ កក្កដា ........ ១៦

⇨ លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច........ ១៧

⇨ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានតួនាទីយ៉ាងសំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ច ការប្រកួតប្រជែង និងការអភិវឌ្ឍ........ ១៩

⇨ កម្ពុជានឹងសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍នៅឆ្នាំ ២០១៥ ក្នុងការផ្តត់ផ្គង់ទឹកស្អាតដល់ប្រជាពលរដ្ឋនៅទីជនបទឱ្យបាន ៥០%........ ២១

⇨ វប្បធម៌ : ប្រយោជន៍ដ៏ធំធេងនៃការដាក់បញ្ចូលបេតិកភណ្ឌវប្បធម៌ជាតិ ជាបេតិកភណ្ឌពិភពលោក.....២៤

⇨ ចំណេះដឹងទូទៅ : វិធីការពាររន្ទះ ........ ២៦

⇨ ទឹកដីមាតុភូមិ : ទៅកាន់ច្រកអានសេះ ពីគ្មានផ្លូវនឹងទៅជាមានផ្លូវកៅស៊ូឆាប់ៗនេះ........ ២៨

⇨ កំណាព្យ : អបអរសាទរថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា....... សំណើច ........ ៣១



**និពន្ធនាយក :**

**លោក តាក ស៊ុនអ៊ី**

**គណៈកម្មការនិពន្ធ**

១. លោក ខៀវ ណារី

២. លោក អ៊ឹម សុន្ទរៈ

៣. លោក វង្ស សារុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

**លេខានិពន្ធ**

១. លោក ជុំ សម្បត្តិ

២. លោក ម៉ក់ ឈិន

**អ្នកបកប្រែភាសា**

១. លោកស្រី ម៉ែន នារីសោភ័គ

**អ្នកថតរូប**

១. លោក សុផាត វីរៈមុនី

**វិចិត្រករ**

១. លោក ធា សារុធ



អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥

**Address :**
**No 203 Preah Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**

ទស្សនាវដ្ដី

# ប្រជាជន

THE PRACHEACHUN MAGAZINE







ឆ្នាំទី១៤ លេខ ១៥៨ ខែកក្កដា ឆ្នាំ ២០១៤



ស្ពានអាកាសស្ទឹងមានជ័យ (សម្ពោធថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៤)

